# កម្ពុជសុរិយា

COMMISSION DES MOEURS & COUTUMES

RÉGIE DU

ទស្សនាវដ្តី ផ្សាយជំនឿខាងសាសនា និងអក្សរសាស្ត្រ. បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ណារក្ស នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកជំនឿសាសនាៈ ព្រះគ្រូសុវណ្ណញាណ សួរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ*


| | | ទំព័រ |
|---|---|---|
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ពាក្យបរិយាយដើមនៃរឿងសាមកុក ....... | ៨១ |
| អ្នកឧកញ៉ាវិបុលរាជសេនា(នូរ-កន) តំណាងរាស្ត្រ | អារម្ភកថានិងរឿងសាមកុក............ | ៩០ |
| អ្នកឧកញ៉ាទេពពិទូរឈឹម ក្រសេម តំណាងរាស្ត្រ | ហ្មេនស្បែក... ...................... | ១០០ |
| ឃុនសុន្ទរមេធី ញ៉ុង-សៀង | ឯកសហស្សរាត្រី ភាគទី១៥ ............ | ១០៩ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ប្រវត្តិសាស្ត្រប្រទេសចិន (តមក)....... | ១២១ |
| លោក រ៉ាយ-ប៊ុក សមុហបញ្ជី | រឿង ស៊ុន-យ៉ាត់-សេន អ្នកនយោបាយឯកជាតិចិន (តមក)..................... | ១៣២ |


*ផ្នែកសាសនា*


| | | |
|---|---|---|
| ព្រះវិន័យធម្ម យូរ-ប៊ុណ្ណ | សង្គហធម៌.............. .......... | ១៤៤ |
| ព្រះគ្រូបញ្ញាលិខិត កៅ-សិម | យុវចរិយាកថា (តមក)............ | ១៥៥ |


ឆ្នាំទី ២១ — លេខ ២ ខែ កុម្ភៈ ឆ្នាំ ១៩៤៨ — ថ្លៃជាវ ១ ឆ្នាំ ៦៨ រៀល ។

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantrī NHOK-THÈM, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah grū Suvaddhañāna SO-HAY membre la Commission du Tripitaka

## TABLE DES MATIÈRES

**Partie littéraire :**


| | | page |
|---|---|---|
| Luong Nibandhamantrī NHOK-THÈM (I.B.) | Introduction à l'histoire de "Sam kok" ..................... | 81 |
| Oknha Vipularājasenā NOU-KAN Député | Histoire de "Sam kok" .......... | 90 |
| Oknha Deb Bidur CHHIM-KRASÉM Député | Théatre d'Ombres Chinois (Lokhon Sbèk)..................... | 100 |
| Khun Sundaramédhi NHOUNG-SŒUNG (I.B.) | Conte "Mille et une nuits" fasc. 15 ... | 109 |
| Luong Nibandhamantrī NHOK-THÉM (I.B.) | Histoire de Chine (suite) .......... | 121 |
| Monsieur RAY-BUC Chef Comptable (I.B.) | Un épisode de la vie du Dr. Sun-Yat-Sen, (suite)................ | 132 |


**Partie religieuse:**


| | | |
|---|---|---|
| Vén. Brah Vinayadhamma YOU-PONN membre de la Commission du Tripitaka | Sangahadhamma ................. | 144 |
| Vén. Brah grū Paññālikhit KAO-SIM professeur de l'Ecole supérieure de Pali | Yuvacariyākathā (suite) ......... | 155 |


20e Année: n° 2 Février 1948 — Prix d'abonnement 68$00 par an.

# ពាក្យបរិយាយដើមនៃរឿងសាមកុក

របស់

## ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម

រឿងសាមកុកនេះ ជារឿងក៏ផ្តួត ១ ក្នុងពង្សាវតារចិន កាលពីក្នុងរវាងខាងចុងសតវត្សរ៍ទីពីរនិងខាងដើមសតវត្សរ៍ទីបី នៃគ្រិស្តសករាជ ។ កាលចាប់ផ្តើមកើតរឿងឡើង គេមិនបានកត់ត្រាជាអក្សរទុកមកតាំងពីដំបូងទេ គ្រាន់តែជារឿងនិយាយជំណាលត ៗ គ្នាមក ៗ ដល់សម័យតមកក្រោយទៀត ប្រជាជនជាតិចិននិយមយករឿងសាមកុកនេះទៅតែងលេងល្ខោន ដែលយើងហៅថាលេងហ៊ី ទើបនាំឲ្យរឿងសាមកុកនេះសាយភាយពេញទៅ មានអ្នកចេះដឹងរឿងកាន់តែច្រើនឡើង ៗ ទើបអ្នកប្រាជ្ញចិនរួបរួមចងក្រងកត់ត្រាជាអក្សរទុកតមក ៗ ដល់សម័យស្រុកចិនចេះធ្វើពុម្ពអក្សរហើយ គេបានបោះពុម្ពផ្សាយរឿងសាមកុកនេះជាសៀវភៅឡើង ជាដើមហេតុឲ្យរឿងសាមកុកសាយភាយទូទៅក្នុងប្រទេសចិន រហូតដល់នានាប្រទេសផង ។

បើយើងពិគ្រោះមើលសេចក្តីក្នុងរឿងនៃសាមកុកនេះនឹងយល់ថាអ្នកនិពន្ធរឿងនេះ មានបំណងចងក្រងក្នុងរឿងឲ្យទៅជាគ្រឿងសម្រាប់សិក្សាខាងផ្នែកនយោបាយស្រុកទេសផង ខាងផ្នែកក្បួនកលក្នុងសឹកសង្គ្រាមផង ហើយតែងបានល្អហូរហៃ គួរឲ្យសរសើរដល់គំនិតនិងសេចក្តីព្យា-

យាមរបស់អ្នកនិពន្ធរឿងសាមកុកនេះណាស់ ។ ហេតុនេះហើយបានជា រឿងសាមកុកនេះបានផ្សាយចេញទៅ មិនត្រឹមតែក្នុងស្រុកចិន រហូត ដល់នានាប្រទេសផង ៕

ចំពោះប្រទេសសៀម គេបានប្រែរឿងសាមកុកចេញពីភាសាចិន ជាលើកដំបូង កាលពី ព. ស. ២៣៤៩ ក្នុងសម័យដែលមិនទាន់មាន កេនពុម្ពសម្រាប់បោះពុម្ពសៀវភៅនៅឡើយ ។ ដល់សម័យកើតកេនពុម្ព សម្រាប់បោះពុម្ពសៀវភៅផ្សេងៗបានហើយ គេក៏បានចាត់ការបោះពុម្ព រឿងសាមកុកនេះផ្សាយជាច្រើនលើកដែរ ។ រឿងសាមកុកដែលគេ បានចាត់ការបោះពុម្ពលើកក្រោយបង្អស់គឺ ព. ស. ២៤៧០ ប្រហែល ជាពុម្ពបោះពុម្ពលើកក្រោយនេះហើយ ដែលអ្នកឧកញ៉ាវិបុលរាជសេនា (នូ) តំណាងក្រសួ បានប្រែចេញជាខេមរភាសាចប់សព្វគ្រប់ តែ គ្មានឱកាសនឹងបោះពុម្ពផ្សាយរឿងនេះ អស់ជាច្រើនឆ្នាំ ។ ក្រោយ បំផុតលោកបានយកសំណៅប្រែរឿងសាមកុកមកប្រគល់ឲ្យពុទ្ធសាសន- បណ្ឌិត្យ ដើម្បីឲ្យចាត់ការបោះពុម្ពផ្សាយតាមត្រូវការ ។ យើងសូម គោលជាតំណាងនៃគណនាមពុទ្ធសាសនបណ្ឌិត្យ សូមសំដែងអំណរអរគុណ ចំពោះអ្នកឧកញ៉ាវិបុលរាជសេនា (នូ) ហើយសូមសរសើរសេចក្តី ព្យាយាមដែលបានខំខ្វល់ខ្វាយប្រែរឿងដ៏វែងនេះត្រាតែចប់សព្វគ្រប់ ។ ប៉ុន្តែក្នុងឱកាសសព្វថ្ងៃនេះ ពុទ្ធសាសនបណ្ឌិត្យមិនអាចចាត់ការបោះពុម្ព

ផ្កាយជាសៀវភៅជាប់ដោយខ្សែរទៅបាន ទើបនាំយករឿងនេះមកបុ ផ្កាយក្នុងទស្សនាវដ្តី កម្ពុជសុរិយា នេះជាបណ្តើរៗ ទៅសិន ។

ឯដំណើររឿងសាមកុកនេះ បើសរុបសេចក្តីឲ្យខ្លីតាមអត្ថាធិប្បាយរបស់ក្រុមព្រះដាំរុងរាជានុភាពអ្នកប្រាជ្ញប្រវត្តិសាស្ត្រជាតិថៃ ដូចមានសេចក្តីតទៅនេះ ។

"រឿងសាមកុកនេះ ចាប់ផ្តើមមានរឿងកើតឡើង ក្នុងរជ្ជកាលព្រះបាទឡេនតេ កាលពី ព.ស. ៧១១ (ត្រង់ គ.ស. ១៦៨) ដែលជាបឋមហេតុបណ្តាលឲ្យអាណាចក្រចិនបែកខ្ញែកចេញទៅជា ៣ ភាគ ដែលចិនហៅថា "សាមកុក" ។ ព្រះមហាក្សត្រព្រះអង្គនេះ គ្មានសមត្ថភាព ទ្រង់ជឿស្តាប់ពាក្យខ្លូលញុះញង់របស់ពួកខន្ទី (ពួកមនុស្សប្រុសករៀវក្នុងព្រះរាជសំណាក់) ពួកមន្ត្រីតូចធំក្នុងក្រុង ក៏គ្មានអ្នកណាមួយខ្វាយខ្វល់ លួមជាទីគោរពគោតក្រុងរបស់ខ្លួនទៅ រាជការផែនដីក៏ល្អៀងល្អៀងឃ្លាតចាកផ្លូវសុចរិតយុត្តិធម៌ ពួកចោរកំណាចកើតឡើងបានខ្លះ ដរាបដល់ទ្រង់ទិវង្គតទៅ ។ ក្សត្រព្រះអង្គនេះ ទ្រង់មានព្រះរាជបុត្រ ២ ព្រះអង្គ ព្រះអង្គច្បងព្រះនាមហាន់ជូពៀន ទ្រង់ទទួលគ្រងរាជ្យជាតំណព្រះរាជវង្ស តែព្រះនាងហូហៅ ជាព្រះវរជននីស្តេចការផែនដីជំនួស ព្រោះព្រះរាជបុត្រនៅកុមារណាស់ ។ ព្រះរាជបុត្រ អនុជព្រះនាម ហាន់ជូហៀប កំព្រាព្រះជននី នាងតាំងថៃហៅ ជាអយ្យិកា

ចិញ្ចឹមតាំងពីនៅជាទារក ហើយខំខ្វល់ខ្វាយចង់ឲ្យទៅបានរាជសម្បត្តិ ទើបនាំងតាំងពីនោះទៅជាអាទិនិត្តា ។ ក្រោយព្រះបាទខៀនតេទិវង្គតទៅនោះ ហូជិនជាបងព្រះនាងហូហៅ បានធ្វើជាមន្ត្រីធំ ក្នុងព្រះរាជវាំង ធ្វើកលឧបាយឲ្យគេសម្លាប់នាងតាំងថៃហូទៅ ហើយគិតកំចាត់ពួកខន្ទីចេញទៀត ប៉ុន្តែ ព្រះនាងហូហៅកំពុងការពារពួកខន្ទី ៗ គមត ហូជិនលបមានចុតហ្មាយសំងាត់ទៅផ្ដល់តាំងតុ ចៅហ្វាយស្រុកឈី-ឡុង ឲ្យលើកទ័ពចូលទៅបង្រាបពួកខន្ទី ៗ បានដឹងរឿង ក៏ធ្វើកលល្បួងឲ្យហូជិនចូលទៅក្នុងវាំង ព្រួតដៃគ្នាចាប់ហូជិនសម្លាប់ទៅ ។ ខាងពួកហូជិនបានដឹងដំណឹងនោះ ក៏នាំគ្នាដុតព្រះរាជវាំង ហើយលើកគ្នាចូលលុកលុយកាប់សម្លាប់ពួកខន្ទីជាបលាបល ។ ក្សត្រត្រង់រាជ្យទ្រង់គេចរត់ទៅស្នាក់នៅទីដទៃ ។ ឯតាំងតុកាលបានឱកាសជាប្រយោជន៍ដល់ខ្លួន ក៏លើកទ័ពចូលក្រុង បង្រាបការចលាចលរួចរាល់ហើយ ទើបដកព្រះមហាក្សត្រ និងព្រះនាងហូហៅជាព្រះវររាជនី ចេញចាករាជសម្បត្តិ លើកហាំងជូហៀប ជាព្រះអនុជឡើងគ្រងរាជ្យ ទ្រង់ព្រះនាមព្រះបាទហៀន-តេ តាំងតុក៏តាំងខ្លួនឯងជា "សៀងកុក" (តំណែងអគ្គមហាសេនាប-តី) សម្រេចពុំការផែនដី ។ កាលតាំងតុបានឡើងជាសៀងកុកហើយ ក៏តាំងប្រព្រឹត្តអំពើខុសច្បាប់ផ្សេងៗ ពួកមន្ត្រីនៅក្រុង គ្មានអ្នកណាមួយអាចកំចាត់តាំងតុចេញ ក៏នាំគ្នារត់ចេញទៅនៅខេត្តក្រៅអស់ជាច្រើន ។

ក្នុងចំណោមពួកដែលរត់ទៅនោះ មានមន្ត្រីពូកែម្នាក់ឈ្មោះប៊ូចូ បាន បបួលចៅហ្វាយស្រុកជាច្រើនស្រុកលើកទ័ពទៅបង្ក្រាបតាំងកុ ប៉ុន្តែ ធ្វើការមិនសម្រេច ព្រោះមិនរួមសាមគ្គីគ្នា ដោយចៅហ្វាយស្រុកអស់នោះ គិតតែចង់បានប្រយោជន៍ទឹកដីសំណាប់តែសព្វ ១ ខ្លួន ម្ល៉ោះហើយទៅជាទាស់ទែងច្បាំងតែគ្នាឯង ៗ

តមមកមិនយូរប៉ុន្មាន គង់ស៊ុនជាមន្ត្រីធំនៅទីក្រុងក៏គិតធ្វើកលឧបាយកំចាត់តាំងកុចេញបានសម្រេច ដោយយកស្រីរូបឆោមឆើតធ្វើជានុយ ប៉ុន្តែ គង់ស៊ុនមិនអាចចាត់ការស្រុកទេសឲ្យរៀបរយទៅបាន ថែមទាំងក្បត់ទ្រង់កផ្សក៏ឥតសមត្ថភាព ទើបជាហេតុឲ្យបក្ខពួករបស់តាំងកុ មានលិញយុយ គុយគីជាដើម ធ្វើការសងសឹកសម្លាប់គង់ស៊ុនទៅទៀត ហើយបង្ខំឲ្យព្រះបាទហៀនតេ តាំងពួកខ្លួនឲ្យធ្វើជាធំក្នុងទីក្រុង ៗ នៅទីបំផុតពួកនេះគិតកំចាត់ព្រះបាទហៀនតេចេញ ទ្រង់គេចរត់ចោលទីក្រុងទៅ ទ្រង់បានសេចក្តីលំបាកវេទនាជាអនេក ហើយមានព្រះរាជឱង្ការឲ្យហៅប៊ូចូលមកជួយទំនុកបំរុងទ្រង់ ក្នុងឱកាសនោះ ៗ ប៊ូចូលើកទ័ពចូលទៅបង្ក្រាបពួកក្បត់បានរាបទាបនៅទីក្រុង ហើយបានទទួលតំណែងជាសៀង-កុក សម្រេចរាជការផែនដី តែចណ្ណាខេត្តក្រៅៗនៅតែរបះរះបាររឹងទទឹង តាំងពីកាលតាំងកុលិញយុយ-គុយគីមកនោះ ៗ ឯពួកមន្ត្រីដែលរត់ចោលក្រុងទៅក្នុងសម័យតាំងកុ ក៏បានត្រឡប់ចូលមកទីក្រុងវិញ ក្នុងពេល

ដែលបងប្អូនបានធ្វើជាស្មៀនកុងត្រាដោយស្ម័គ្រចិត្តចុះចូលទីនបងប្អូនក៏មាន ដែលនៅស្ងៀម ៗ ចាំមើលបំណាក់ក៏មាន ដែលនៅរឹងទទឹងក៏នៅមាន ។

ឯបងប្អូននេះ ជាមនុស្សមានសតិបញ្ញាវាងវៃជាមេទ័ពមានសមត្ថភាព ជាអ្នកការពារគ្រប់គ្រងបង្ក្រាបបញ្ហាខ្មែរក្រៅនានា អាចធ្វើឱ្យទ័ពក្រុងមានអំណាចមានកំឡាំងកើនចំរើនឡើងជាងកាលជាន់មុននេះ ។ ប៉ុន្តែ បងប្អូនច្រើនធ្វើការតាមតែទំនើងចិត្តខ្លួន ពួកនាម៉ឺនដែលមិនមែនជាបក្ខពួកបងប្អូនច្រើនស្អប់គិតកំចាត់ចេញ តែគ្មាននរណាហ៊ានកំចាត់ចេញទេ ព្រោះពួកនៅក្រុងស្រឡាញ់បងប្អូនដោយភាគច្រើន ។ បងប្អូនប្រើអំណាចមុខក្រសួងផ្លូវហួសពេក ជាហេតុឱ្យព្រះបាទរៀមគេទ្រង់ក្រិព្រះទ័យហាំងខ្ទាំង ផល់ទៅទ្រង់យកព្រះហោរាសារសេរព្រះទង្កាសម្ងាត់ ហៅគេអ្នកស្វាមីភក្តិឱ្យគិតកំចាត់បងប្អូនចេញ ។ ដំណើរនេះផ្សាយដល់ខ្មែរក្រៅ បណ្តាពួកចៅហ្វាយស្រុកដែលមានកំឡាំង មិនមែនជាបក្ខពួកខាងបងប្អូន ក៏យល់ថាបងប្អូនជាសត្រូវទឹងផែនដី ដូចជាតាំងគុំដែរ ទើបនាំគ្នារឹងទទឹងឡើង ។ ឯបងប្អូនដែលប្រកាន់សក្តិខ្លួនជាស្មៀនកុង ក៏យល់ថាត្រូវតែបង្ក្រាបខ្មែរក្រៅដែលរឹងទទឹងជាសត្រូវទឹងផែនដី ទើបជាហេតុឱ្យកើតជាចម្បាំងឡើង ដោយតាំងសង្គ្រាមជាច្បាំងបង្ក្រាបពួកក្បត់ផែនដី ។ ផលនៃការច្បាំងគ្នាជាយូរអង្វែងនោះ បែកខាងឥតរិត

ពួកបារាំងបង្ក្រាបខែត្រក្រៅបានជាចំនួនច្រើន បង្ក្រាបមិនបានតែបណ្ដាខែត្រដែលនៅក្រោមឱវាទស៊ិនកួនទាំងឡាយប៉ុណ្ណោះ ។

ស៊ិនកួន ជាម្ចាស់ស្រុកក្តាំង ជាខែត្រធំ ១ ខាងនៅទិសខាងកើត ជាអ្នកគ្រប់គ្រងស្រុកទេសបានល្អតាំងនៅក្នុងសីលធម៌ មានមនុស្សទ្រិយមកបំការនច្រើន ត្រាតែមានកំឡាំងខ្លាំងពូកែឡើងច្រើន ។ ឯឡៅពីនោះ ដំបូងជាមនុស្សអនាថា តែមានត្រកូលខ្ពស់ជាប់សែស្រឡាយក្នុងរាជវង្សហាន ជាអ្នកមានអធ្យាស្រ័យល្អ ហើយគាប់ចួនបានមនុស្សល្អៗតែមានថ្វីដៃមកចូលធ្វើជានាយទាហានច្រើននាក់ ទើបមានកេរ្តិ៍ឈ្មោះល្បីឡើង គមកបានខុងមេងជាទីប្រឹក្សាខាងសឹកសង្គ្រាម បានណែនាំឲ្យចងមិត្រនឹងស៊ិនកួន ព្រោះដែលគាត់ស៊ូទ្រាំចូលទើបគេក្សាខ្លួនបានសុខ ហើយគាប់ចួនបានខែត្រសេចួនតាំងនៅទិសខាងលិចជាប់ផ្នែក ទើបតាំងឡាក់ហានបានមាំមួន ។ ឯព្រះបាទហៀនតេ ជាព្រះមហាក្សត្រប្រទេសចិនតែព្រះនាមដូចរូបតុក្កតា តែពង្សាវតារចិននៅរាប់ថាជាព្រះមហាក្សត្រប្រទេសចិនទាំងមូល ។

លុះបួនឆ្នាំចូលមកទៅ ពួកជាកូនចៅបានទទួលតំណែងសៀងកុក ជាតំណាងមកជំនួសបិតា រួចបានដកព្រះបាទហៀនតេះចេញពីរាជសម្បត្តិ ហើយប្រកាសតាំងខ្លួនឯងឡើងជាព្រះមហាក្សត្រប្រទេសចិន ផ្លាស់រាជវង្សថ្មីហៅថារាជវង្សវុយ កាលពី គ.ស. ៧៦៣ ។ ចំណែកខាង

ទៀវតី ក៏បានតាំងខ្លួនជាក្សត្រឡើងដែរ ចាត់តាំងរាជវង្សហាន់ឡើងថ្មីទៀតនៅខែត្រដែនសេដ្ឋ ។ ចានស៊ុនកួន មិនចង់នៅចំណុះចូកី ឬទៀវតី ក៏តាំងជាឯករាជ្យឡើងនៅខែត្រដែនកន្លាំង ។ តាំងអំពីកាលណោះមកប្រទេសចិនទាំងមូលក៏បែកខ្ញែកចេញជាសាមកុក គឺបែកចេញជា ៣ អាណាចក្រសឹងមានឥស្សរៈដាច់ដោយឡែកពីគ្នា ។ អាណាខេត្តរបស់ព្រះបាទចូកីហៅថា វុយកុក ។ អាណាខេត្តរបស់ព្រះបាទទៀវតី ហៅថា ចុកកុក ។ អាណាខេត្តរបស់ព្រះបាទស៊ុនកួន ហៅថា ង៉ុកុក ។ តំណើរកាលតមក កាលអស់បុណ្យព្រះបាទទៀវតី ចូកី - ស៊ុនកួនហើយ អ្នកគ្រប់គ្រងប្រទេសជាតំណតមក ជាអ្នកឥតសមត្ថភាពទាំងបីកុក ទើបស៊ីម៉ាអៀវដែលជាអ្នកសម្រេចរាជការនៃដែនចានវុយកុក បង្ក្រាបចុកកុកបានមុន រួចតមក ស៊ីម៉ាអៀន ចុកស៊ីម៉ាអៀវ ដណ្តើមរាជសម្បត្តិវុយកុកបានផ្លាស់រាជវង្សថ្មីហៅថារាជវង្សជិន ហើយបង្ក្រាបង៉ុកុកបាន ១ កុកទៀត ។ ទើបមហាអាណាចក្រចិនត្រឡប់ចូលរួបរួមគ្នាមូលតែមួយបានឡើងវិញ ចប់រឿងសាមកុកដោយសង្ខេបខ្ទីត្រឹមប៉ុណ្ណោះ" ។

(សង្ខេបរយៈសម័យក្នុងរឿងសាមកុកនេះ ដូច្នេះគឺសម័យរាជវង្សហាន់ទៀវតេយ ក្នុងរជ្ជកាលព្រះបាទឡេងតេ ២១ ឆ្នាំ ក្នុងសម័យតាំង

កុក ក្នុងរជ្ជកាលព្រះបាទហៀនតេ ៣០ ឆ្នាំ សម័យសាមកុក ៦០ ឆ្នាំ (ប្រមូលសម័យកាល ក្នុងរឿងសាមកុកនេះជារយៈ ១១១ ឆ្នាំ) ។

នៅទីបំផុត យើងមានសេចក្តីសង្ឃឹមថាអស់លោកអ្នកអានរឿងសាមកុក ដែលជាសេចក្តីប្រែរបស់អ្នកឧកញ៉ាវិបុលរាជសេនា (គន) តំណាងក្រស្ន គង់មានសេចក្តីពេញចិត្តជាយ៉ាងច្រើនមិនខាន ដ្បិតរឿងនេះមានសេចក្តីផ្ទួររឿងជាប់ទាក់ទងគ្នាហូរហែ គួរឲ្យចង់មើលចង់ដឹង ។

ឯអក្ខរាវិរុទ្ធនិងពាក្យពេចន៍ខ្លះ យើងបានពិនិត្យកែសម្រួលទៅតាមសម័យនិយម ដែលលោកអ្នកប្រែបានអនុញ្ញាតឲ្យកែបានតាមត្រូវការ ដូចមានសេចក្តីបញ្ជាក់ក្នុងអារម្ភកថារបស់លោកស្រាប់ ។

---

# អារម្ភកថា

រីសេចក្ដីនៃព្រះពង្សាវតារនៃព្រះមហាក្សត្រ ដែលសោយរាជសម្បត្តិក្នុងមហាប្រទេសចិននោះ អ្នកប្រាជ្ញបុរាណគេបានតែងគម្ពីរ ហៅជាភាសាចិនក្នុងរឿងនេះថា «សាមកុក» មានថៃបដែនប្រែទុកក្នុងក្រុងទេពមហានគរជាភាសាសៀមៗ បុណ្យក្សត្របានចាត់ការឲ្យផ្ទៀងផ្ទាត់តាមប្រវត្តិប្រទេស គឺឃើញជាក់ច្បាស់ថា ក្នុងសម័យសាមកុកនោះជាជំនាន់ក្រោយពុទ្ធកាល ដែលព្រះពុទ្ធជាអម្ចាស់នៃយើងព្រះអង្គទ្រង់បរិនិព្វាន ទ្រង់រំលងទៅហើយបាន ៧៦៣ ព្រះវស្សា ទើបមហាប្រទេសចិនឧប្បត្តិរឿងសាមកុកនេះឡើង គិតតាំងពីពុទ្ធសករាជ ៧៦៣ រហូតដល់ ៨៦៣ ព្រះវស្សា ទើបផុតផែនដីសាមកុកនោះទៅវិញ អាយុផែនដីសាមកុកនោះ រាប់បានពេញ ៦០ ឆ្នាំដោយគណនា ។

ខ្ញុំមានសេចក្ដីប្រាថ្នាចង់ឲ្យបានរឿងនេះ ផ្សាយក្នុងក្រុងកម្ពុជាធិបតីតទៅ ទើបនៅមានចិត្តឧស្សាហ៍ប្រែមកជាភាសាខ្មែរៈពីដើមដល់ចប់ គិតរាប់ជាសេចក្ដី ៧៨ ខ្សែ ដែលមករួមបញ្ចូលគ្នាជាសៀវភៅឲ្យតិចទៅវិញ តិច ៥ ខ្សែជាសៀវភៅ ១ ត្រូវជា ១៥ សៀវភៅ រួមតាំងសៀវភៅចុងបង្អស់ ដែលមានរួមគ្នាតែ ៣ ខ្សែ ១ សៀវភៅនោះផង ។

រីឯការដែលបានស្ថាបនាជាភាសាខ្មែរអធិប្បាយរឿងនេះ គឺសំណោះប្រើពាក្យសំដី តាមសម័យបច្ចុប្បន្ន របៀបពាក្យពេចន៍ពុំសូវល្អិត

ល្អន់ស្រួលពីរោះដូចលោកបុរាណទេ ព្រោះខ្ញុំបេះពាក្យខ្មែរពុំស្មើនឹងលោកសម័យចាស់ ចំណោះសៀមក៏ពុំមានជាក់ច្បាស់មុតមាំ គ្រាន់តែជួយយកលំនាំល្អមឲ្យស្តាប់បានប៉ុណ្ណោះ ពោះបើខ្វះលើសលោះខុសពុំត្រង់ត្រូវខ្លះណាទិមួយ ក៏សូមឲ្យលោក-អ្នកបេះដឹងទាំងឡាយ ជួយកែប្រែអធិប្បាយឲ្យត្រឹមត្រូវឡើងផងចុះ ព្រោះរឿងនេះចំពោះជាបុរាណសាស្ត្រកាចនឹងញុំាងឲ្យចៀវឆ្លាស ទូរសតិបញ្ញាបេះដេបការសំដីវៃស្គាល់យល់គំនិតចិត្តមនុស្សល្អនឹងអាក្រក់គ្រប់ប្រការ ហើយនឹងជាទីនាំគាត់ឲ្យប្រព្រឹត្តនាំសត្យានុស័ត្យពិតត្រង់ត្រូវតែជាតិ បុរាណមានគំនិតមារយាទគួរសិក្សាឲ្យបេះដឹងរឿងនេះ ទុកជាគ្រឿងប្រដាប់សម្រាប់សតិប្រាជ្ញាឲ្យបានទើបនឹងចំរើនមានទូរសិរីសួស្តីវឌ្ឍនា ការជាគ្រសេមសុខនិរទុក្ខាមហាប្រសើរតទៅ ។

អ្នកឧកញ៉ាវិបុលរាជសេនា កន ភូឈ្មួយសេនាបតី

រិត្រេត៍

ភ្នំពេញ, នៅថ្ងៃ ២៧ ខែមេីឆ្នាំ ១៩៣៣

ត្រូវនឹងថ្ងៃ ១ កើតខែចេត្រឆ្នាំរកានៅឆាបញ្ចាស័ក ព. ស. ២៤៧៦ ។

# រឿងសាមកុក

## វគ្គទី ១

ដើមឡើយផែនដីនៃមហានគរចក្រចិនទាំងមូល រាប់តាំងពីមុនជាន់សាមកុកឡើងទៅនោះ ក៏ជាសុខរៀងមកយូរណាស់, ក្រោយនោះក៏កើតជាសឹកសង្គ្រាម លុះសង្គ្រាមស្ងប់ក៏ត្រឡប់ជាសុខវិញ ។ ជំណាក់អំពីសម័យនោះមកមានព្រះមហាក្សត្រសោយរាជសម្បត្តិក្នុងមហានគរចក្រចិនទ្រង់ព្រះនាមព្រះចៅជីវប៊ូគង រំលងពីនោះមកមានព្រះមហាក្សត្រសោយរាជសម្បត្តិជាលំដាប់គ ១ មកទៀត ជាច្រើនព្រះអង្គសឹងជាសុខក្សេមក្សាន្ត គណនាបាន ៧០០ ឆ្នាំ មហានគរចក្រចិនក្នុងជាន់នោះ មាននគរតូច ១ ចំនួន ៧ មណ្ឌល, ឯកដណាទីក្រុងដែលស្តេចគង់នៅ ១ ក្នុងនគរជិនកុកហៃ ។ ព្រះចៅជីវប៊ូគង់ក៏វាយយកបានមណ្ឌលទាំង ៧ មកជាចំណុះនៃព្រះអង្គរួមជានគរចក្រ ១ ។ ព្រះមហាក្សត្រជាលំដាប់ជាន់ក្រោយនោះទ្រង់ព្រះនាមព្រះចៅជិនអង ទ្រង់កើតសង្គ្រាមបាក់យេនទឹងហានឆ, ក្រោយនោះហានធនឹងហានគូបច្បាំងគ្នាទៀតក៏បានរាជសម្បត្តិទៅហានគូបវិញ, ហើយមានព្រះរាជវង្សជាដំណតពីស្តេចហានគូបសោយរាជ្យជាលំដាប់តមតទៀត រាប់បានចំនួន ១២ អង្គក្សត្រ ។ គ្រានោះមាននាហ្មឺនធំម្នាក់ឈ្មោះអងម៉ាំងប្រែចិត្តក្បត់ដណ្តើមយករាជសម្បត្តិបានហើយតាំងខ្លួនជាម្ចាស់ផែនដីសោយរាជ្យបាន ១៨ ឆ្នាំ ។ ក្រោយ

នោះមានព្រះរាជវង្សស្ដេចហាន់គួប. ព្រះនាមហាន់គង់ប៊ូសម្លាប់អង់ម៉ាំង ចេញបានហើយឡើងសោយរាជសម្បត្តិតមកទៀត ។ លំដាប់ក្សត្រសោយរាជ្យតពីស្ដេចហាន់គង់ប៊ូមកមានចំនួន ១២ អង្គក្សត្រ, ឯស្ដេចដែលសោយរាជ្យចុងបំផុតនោះទ្រង់ព្រះនាមព្រះចៅហាន់តេ, ក្នុងចុងរាជ្យនេះ ផែនដីស្រុកចិនបែកជា ៣ អ្នកភាសាចិនហៅថា "សាមកុក" ព្រោះមានស្ដេចជាម្ចាស់ផែនដី ៣ ព្រះអង្គគ្រងមហាណាចក្រចិននោះ ។

ក្នុងសម័យនោះព្រះចៅរាជាធិរាជ ហាន់តេ មិនមានព្រះរាជបុត្រសោះ បានសុំឈ្មោះឡេងតេជាវង្សវែមកចិញ្ចឹមជាព្រះរាជឱរស, ព្រះចៅហាន់តេទិវង្គតទៅ ឡេងតេបានសោយរាជ្យមានព្រះរាជឱរស ២ ព្រះអង្គ ព្រះរៀមនាមហាន់ជូពៀន, ព្រះអនុជនាមហាន់ជូហៀប ។ កាលក្នុងរាជ្យព្រះចៅឡេងតេនោះ ស្ដេចនេះមិនបានតាំងនៅក្នុងទសពិធរាជធម៌ តាមបុរាណរាជប្រវេណី ហើយមិនបានសេពគប់នឹងអ្នកមានគម្រិះប្រាជ្ញ សុចរិតទៀងត្រង់ទំនុកផែនដីឡើយ, គាប់ព្រះទ័យប្រមាទវង្វេងដោយល្បែងពាល បណ្ដោយឲ្យជឿកាន់យកតែតាមសំដីមនុស្សអន្ធពាល អសត្យ ប្រព្រឹត្តទៅតាមអំពើចិត្តទុច្ចរិតលាមក ផែនដីកើតកលិយុគវិបរិតទៅផ្សេងៗ ។ ខណៈនោះមានពួកខន្ទី[១] ដែលនៅគាល់បំរើ

---

១ ជាពួកមនុស្សប្រុសកម្រៀវ ជាពួកអ្នករាជការខាងក្នុងព្រះរាជវាំង តាមទំនៀមស្រុកចិនសម័យបុរាណ ។

ផ្ទាល់ព្រះអង្គ មានអំណាចញុំាងស្ដេចឲ្យលុះនៅតាមឧបាយកុប្បកលផ្សេងៗ បាន ។ មានខុនម្នាក់ឈ្មោះថៅជៀកជាធំលើសខុនឯទៀត ឃើញព្រះចៅទៀន ឥតធ្វើសស្មារតីយកព្រះទ័យទុកដាក់ស្រឡាញ់ខុន ក៏កើតចិត្តគិតទំនើងក្រួតក្រតាំងធ្វើអំពើលាមកផ្សេងៗ, សូម្បីកិច្ចរាជការបណ្ដាដែលមាននៅក្នុងព្រះរាជអាណាចក្រមណ្ឌលទាំងប៉ុន្មាន ក៏ព្រះរាជាបណ្ដោយឲ្យសម្រេចនៅលើពួកខុនទាំងអស់ ព្រោះខុនជាអ្នកចាំលួចពិតគិតតែកម្រៃឲ្យត្រូវទៅតាមអំណាចស្ម័យនៃខ្លួនដែលមានប្រយោជន៍, គ្រានោះ បណ្ដាអស់ពួកនាហ្មឺនសព្វមុខមន្ត្រីតូចធំរាជការ អាណាប្រជារាស្ត្រទាសកម្មករទាំងឡាយ ក៏កើតសេចក្ដីក្ដៅក្រហាយទួញទាំងព្រះនគរ ។

ខណៈនោះមានមន្ត្រីធំៗ ពីរនាក់ដែលជាមនុស្សស្មោះត្រង់នឹងផែនដី ឈ្មោះតៅប៊ូ ១ តាន់គួន ១ បានឃើញស្ដេចវង្វេងភ្លេចស្មារតីយកព្រះទ័យទុកដាក់ស្មើតែស្រឡាញ់ពួកខុនទាំងឡាយ ក៏គិតគូររកឧបាយនឹងសម្លាប់ពួកខុនទាំងនោះចោលចេញ ។ ឯថៅជៀកខុននោះដឹងខ្លួនភ្លាមក៏ញុះញង់ឲ្យពួកខុនទាំងឡាយ រកឧបាយចាប់យកតៅប៊ូ នឹង តាន់គួនទាំងពីរនាក់ទៅសម្លាប់ចោល, លុះធ្វើសម្រេចកិច្ចដូចប្រាថ្នាហើយ ថៅជៀកនឹងខុនទាំងនោះក៏រឹតតែខ្វល់ខ្វាយក៏កើតចិត្តឥតខ្លាចអ្នកណាឡើយ ។

លុះអំណើះពីនោះមកព្រះចៅទៀនកេ សោយរាជសម្បត្តិបាន ១២ ឆ្នាំ ជាទោស័កថ្ងៃ ១៥ កើតខែផល្គុន ព្រះអង្គទ្រង់ចេញប្រថាប់លើព្រះទីនាំងកៅអីក្នុងទីប្រាសាទ (អ៊ុនកុងតៀន), នៅវេលាថ្ងៃត្រង់ជាក់ កំបណ្តាលឲ្យឃើញអាកេទធ្លាក់ខ្យល់ព្យុះសង្ឃ្រពជាអស្ចារ្យណាស់ ឃើញមានពស់ ១ ធំសម្បើម សម្បុរខៀវធ្លាក់ចុះមកពីលើអាកាសនៅទីចំពោះព្រះភក្ត្រ ហើយពស់ក៏គេចលូនឡើងព័ទ្ធរុំជើងព្រះកៅអីដែលស្តេចគង់ ព្រះអង្គទ្រង់ស្ទុះព្រះទ័យភ័យតក្កមាធ្លាក់ព្រះកាយពីលើព្រះកៅអី ដួលសន្លប់ចុះលោះបាត់ព្រះស្មារតីពុំដឹងព្រះអង្គសោះ, ពួកនាហ្មឺនទាំងអស់បានឃើញគ្រប់គ្នាក៏ភ័យម៉ម៉ាស្ទុះទៅប្រពាក់ប្រពួន ខ្វះប្រែះខ្ទួនលូនចូលទៅលើកគ្រែ ហើយនាំព្រះកាយចូលទៅកាន់ព្រះមន្ទីរខាងក្នុង, ឯពស់នោះក៏អន្តរធានបាត់ទៅវិញមួយរំពេច ។ លំដាប់នោះក៏បង្កើតជាផ្គររន្ទះអសនីបាញ់ខ្ទរខ្ទើរញ័រកក្រើកអស់ទាំងផែនដី ស្ទើរតែក្លុកក្រឡាប់, មេឃក៏ចុះអ័ព្ទងងឹតបិទសូរ្យតែរង ព្រះពិរុណក៏រលាជាភ្លៀងធ្លាក់ផ្គ្រោលាយទៅដោយគ្រាប់ព្រិលធំ ៗ បំមកលើផ្ទះសម្បែងមហាជនរលំរលើនដួលគរលើគ្នាជាកោលាហលពេញនគរ, បណ្តាពស្ត្រីសីនតែផ្អើលភ្លួកវិតវរជ្រួលច្របល់, លុះដល់ថ្ងៃរសៀលទើបស្ងប់ខ្យល់ពីងភ្លៀង ។ រំលងពីនោះមក ៤ ឆ្នាំដល់រដូវប្រាំងក្នុងខែបុស្សស្រុកខ្លុកអៀងនោះជារាជធានីព្រះនគរណាក៏តែក្រេកអំពើកញ្ជាប់ញ័រងង ទឹកទន្លេឡើងលិចអស់ភូមិករណ៍

ផ្ទះសម្បែងអ្នកស្រុកដែលនៅក្បែរមាត់កំពង់ រលំរលើងរលើងយង់អណ្តែត ទៅតាមទឹកជ្រោះអស់, ពេលនោះប្រែខ្លួនមាន់ញីទៅជាមាន់ឈ្មោល ។

លុះដល់ថ្ងៃ ១ កើតខែពិសាខឆ្នាំនោះកើតបុព្វនិមិត្តជាភ្លើងឆេះឡើង មានអណ្តាតប្រហែល ២០ ព្យាម (៤០ ម៉ែត្រ) បក់ចោតត្រឡប់អណ្តាត ទីងផ្សែង ចូលទៅក្នុងល្អាងព្រះទីនាំង អ៊ុនតុកកៀន ។ ដល់មកខែជេស្ឋ ក៏កើតបុព្វនិមិត្តមួយទៀត ជាពន្លឺរស្មីដ៏រុងរឿងធ្លាក់ចុះមកពេញព្រះរាជវាំង, ឯក្អក់ទស្វដែលមានទំហំធំហើយខ្ពស់ជាងគេនោះ ក៏បណ្តាលទៅជាបែក ធ្លាយពីកំពូលចុះមកយ៉ាងអស្ចារ្យ ។ ព្រះចៅឡេខេទ្រង់ពិភាល់ក្នុង ព្រះទ័យពេកណាស់ក៏ត្រាស់សួរទៅពួកនាហ្មឺនសព្វមុខមន្ត្រីតូចធំទាំង-ឡាយថា «និមិត្តបរិកប្បនេះកើតនឹងល្អឬអាក្រក់ប្រការដូចម្តេច ?» យើងឡើង ជានាហ្មឺនធំនេះដឹង ក៏តាំងសរសេរជាសំបុត្រសង្ខាត់ក្រាបទូលថា «ហេតុដែលបណ្តាលឲ្យឃើញអស្ចារ្យដូច្នេះ មិនមកពីអ្វីទេ គឺមកពីពួកខ្ញុំអប្រិយប្រព្រឹត្តបរិតក្កនូវព្រះរាជប្បវេណីគ្រប់ប្រការនោះឯង បានជាបណ្តាលឲ្យកើតនិមិត្តអស្ចារ្យប្លែកដូច្នេះ, ដើម្បីឲ្យព្រះអង្គទ្រង់ឃើញ ហើយត្រិះរិះតាមគួរដំការ" ។ ព្រះចៅឡេខេទតចប់សេចក្តីហើយ ក៏មានព្រះទ័យបរិតក្កជាទុក្ខ ទ្រង់ដកដង្ហើមធំ តែមិនបានមានព្រះបន្ទូលថាដូចម្តេចឡើយ ទើបស្តេចក្រោកចាកអាសនាផ្ចង់ព្រះក្ខុសាចូលព្រះអង្គឆ្លង ។ ពេលនោះទទួលទៅបៀតចំនួន ចូលទៅក្រាបបង្គំលាពីក្រោយព្រះទីនាំង

បានក្រឡេកទៅឃើញលិខិត ដែលស្ដេចកំពុងទតជីងសេចក្ដីប្រាស់ជាលិខិតរបស់យើឡុងធ្វើក្រាបបង្គំទូលប្ដឹង ក៏ថយមកពិគ្រោះនឹងបក្សពួកវិញថា "យើងត្រូវរកឧបាយដូចម្ដេចឲ្យបានសេចក្ដីខុសនេះ ធ្លាក់ទៅលើយើឡុងជាយ៉ាងសាហាវ ដើម្បីនឹងឲ្យស្ដេចធ្វើទោសយើឡុងនោះបញ្ចាកអំពីសក្ដិយសជាមន្ត្រីឲ្យបាន" ។

ឯពួកខន្ទីដែលជាមេធំ ៗ នោះមាន ៩ នាក់ គឺឈ្មោះថៅជៀត ១ តៀវគុង ១, តៀវយៀង ១, ហានស៊ី ១, កួនគុយ ១, ហៅចូ ១, គៀនសុត ១, ហេហ៊ុយ ១, កាំឡុង ១, បើមន្ត្រីឯណាមិនបាននៅក្នុងឱវាទ ស្ដាប់បង្គាប់នៃពួកខន្ទីទាំងនោះ ក៏ឲ្យដកហូតងារចេញពីរាជការ, អ្នកឯណានៅក្នុងបង្គាប់បញ្ជា គឺតែងតាំងលើកដំកើងឲ្យឡើងយសសក្ដិជាមន្ត្រីតូចធំតាមចិត្ត ។ ឯថៅជៀតនឹងពួកខន្ទីទាំងនោះ ក៏តាំងឈ្មោះខ្លួនជា "ស៊ិបសៀងស៊ី" ព្រះចៅហ្លួនតេ ក៏យកព្រះទ័យទុកដាក់ជឿកាន់យកតាមពាក្យសំដីនៃឈ្មោះតៀវយៀងខន្ទី, សន្មតហៅថា "ព្រះបិតាធម៌", ឯផ្ការនឹងច្បាប់ទំលាប់ស្រមាច់ផែនដីក៏កន្លែប្រែទៅ, បណ្ដាអាណាប្រជាកស្ត្រតាសកម្មករទាំងឡាយ ក៏មានសេចក្ដីក្ដៅក្រហាយជាចលាចលកល់ក់បន់ កើតចោរកំណាចលួចប្លន់កាប់សម្លាប់គ្នាជារីករាលដាលក្រៃណាស់ ។

ប៉ែកខាងស្រុកគីឡុកគុននោះមានបុរសបងប្អូន ៣ នាក់ ឈ្មោះតៀវគុក ១, តៀវប៉ូ ១, តៀវលៀង ១, ឯឈ្មោះតៀវគុកនោះ ជាអ្នក

ដើរស្វែងរកថ្នាំលើភ្នំគូលេន ហើយបានជួបប្រទះនឹងតាចាស់ម្នាក់មុខមាត់ពណ៌សម្បុរដូចជាទារក ភ្នែកលឿង ដៃកាន់ឈើច្រត់ តាចាស់នោះក៏នាំតៀវកុកចូលទៅក្នុងរូងភ្នំ ហើយឲ្យក្បួនគម្ពីរ ៣ ច្បាប់ឈ្មោះ "ថៃផេងយ៉ៅស៊ុក" ហើយប្រាប់ថា "ចូរអ្នកយកគម្ពីរនេះទៅជួយទំនុកបំរុងមនុស្សទាំងឡាយឲ្យបានសេចក្ដីសុខសប្បាយចុះ តែបើខ្លួនអ្នកមានចិត្តមិនទៀងត្រង់គិតប្រទុស្តណាយ ទំនងជាអាវផងនឹងវេលាណាភ័យអន្តរាយនឹងកើតមានដល់ខ្លួនអ្នកវេលានោះ" តៀវកុកក៏លុតជង្គង់ក្រាបសំពះហើយដកបស្សួរថា "ខ្លួនលោកនេះជាអ្វី" តាចាស់នោះឆ្លើយប្រាប់ថា "យើងជាទេវតា" ថាហើយក៏អន្តរធានបាត់ទៅ ។

ឯតៀវកុក លុះបានគម្ពីរនេះហើយ ក៏ខ្មីខ្មារៃត្រឡប់មកកាន់ទីលំនៅខ្លួនវិញ ខំរៀនទន្ទេញតាមគម្ពីរនោះទាំងថ្ងៃទាំងយប់ដរាបដល់តែចេះចាំចាក់ស្ទាត់ អាចសូត្រហៅខ្យល់ហៅភ្លៀងបានគ្រប់ប្រការទើបតាំងខ្លួនជា "គួយ៉ិន" ប្រែជាភាសាខ្មែរថា អ្នកចេះដឹងយ៉ាងវិសេស" ។

គ្រានោះ នៅស្រុកគីឡុកគុន ពួកអ្នកស្រុកកើតជម្ងឺជាច្រើន, តៀវ-កុកបានដឹងហើយក៏សរសេរជាលេខយន្តមន្តតាមគម្ពីរយកទៅចែកឲ្យពួកអ្នកស្រុក ៗ នោះទាំងប្រុសទាំងស្រី ដើម្បីបំបាត់ជម្ងឺយ៉ាងសក្តិ

សិទ្ធិផុតដាច់ពូកែណាស់ ។ មនុស្សម្នាមហាជនក៏ជឿស្រឡាញ់រាប់អាន តៀវកុកទុកជាគ្រូអាចារ្យប្រៀនប្រដៅចំនួនជាងរយនាក់ ។

តាំងពីពេលនោះមក តៀវកុកក៏ទំដើរស្វះស្វែងព្យាបាលរោគា-ពាធតាមស្រុកតូចស្រុកធំនិងតាមជនបទនានា អ្នកណាបានរៀនយន្តមន្តថារបស់តៀវកុក យកទៅក្រោកទុកលើផ្ទះ ក៏បានជាផ្ទះសម្បែងគេស ដើម្បីកាត់ឥតមានភ័យបារម្ភអ្វីឡើយ ។ បណ្តាជនក្នុងស្រុកតូចធំសឹងនិយមរាប់អានមានទ្វេឡើងរាល់ៗថ្ងៃ ។ តៀវកុក ក៏រះកើតមានលាភ-សក្ការៈ ទាំងមនុស្សម្នាមហាជនចុះចូលជាសិស្សគណច្រើនហើយ ទើបតាំងសិស្សគណទាំងនោះឲ្យធ្វើជាភ្នាក់ងារឃុំគ្រប់ៗ អន្ទៀវប្រហែលជា ១០ ដំបន់តំបន់ធំ ១ មានមនុស្សចំនួន ២ ម៉ឺនប្រាំនាក់, ឯដំបន់តូចៗ មានមនុស្សចំនួន ៦ ពាន់ ឬ ៧ ពាន់នាក់, មានមេកាន់កាប់ក្បាលស្រុកតាមលំដាប់ហើយមានទង់ជ័យសម្រាប់បញ្ចាំងគ្រប់ៗ ដំបន់ ។

តៀវកុកតាំងខ្លួនជាពុងនុន (ស្តេចត្រាញ់) ហើយក៏តែងឲ្យបាយឲ្យខ្មឹព្ទទៅថា ផែនដីទីនក័ត្ដប្រែជាបលាបលហើយ ព្រោះមានអ្នកមានបុណ្យមកគ្រងផែនដីជាថ្មី ស្រុកទេសទីងបានសុខសប្បាយ ហើយឲ្យយកក្តារលាបពណ៌សសរសេរជាអក្សរ ២ តួ ទុកនៅមុខខ្លោងទ្វារផ្ទះថា “ឆ្នាំជូតស្រុកនឹងបានសុខសប្បាយ” ។ (មានត)

# ល្ខោនស្បែក (ណាំង)

ឧកញ៉ាទេពពិទូរ ក្រសេម គន្ធបណ្ឌិត រៀបរៀង

## មហោស្រព

## ភាពស្បែកល្ខោន

ការលេងមហោស្រពមួយយ៉ាងដោយប្រើរូបស្បែក ដែលឆ្លាក់ជារូបតាមរឿង ហៅថា ភាពស្បែកល្ខោន សឹងមានលក្ខណៈប្រហែលគ្នានឹងល្ខោនមនុស្សធម្មតា ។

រឿងសម្រាប់លេង គេកំណត់លេងតែរឿងដែលទាក់ទាមដោយរឿងព្រះឥសូរ ព្រះនារាយណ៍ ដូចយ៉ាងរឿងរាមកេរ្តិ៍ជាដើម ដើម្បីជាកិត្តិយសដល់ព្រះជាម្ចាស់អំបាល់នោះ ដូចគ្នានឹងល្ខោនខោល រឿងឯទៀតក្រៅអំពីនេះមិនដែលមានទំនៀមទម្លាប់ទេ ទាំងមិនបានលេងជាប្រក្រតីដូចល្ខោនផង មានលេងម្ដងមួយកាលចំពោះតែក្នុងវេលាដែលមានពិធីបុណ្យធំៗ ដូចយ៉ាងបុណ្យចំរើនព្រះជន្ម និងបុណ្យថ្វាយព្រះភ្លើងជាដើម ។ ហេតុដែលមិនបានលេងជាប្រក្រតី មកពីរូបល្ខោនដែលសម្រាប់លេងនោះមានតែ១សម្រាប់ ដូចយ៉ាងទំនៀមដែលលេងក្នុងកាលឥឡូវនេះ មានតែរូបរឿងរាមកេរ្តិ៍ប៉ុណ្ណោះ ក្រៃការលេងវេលាណាក៏យករូបនោះចេញលេងរាល់ដង ទាំនឹងធ្វើរូបឲ្យប្រែតាមក្នុងរឿងផ្សេងៗ ទុក

លេង កំពុះសោហ៊ុយច្រើនណាស់ ពាំងគ្មានចំនៀមទម្លាប់លេងដូច គោលហើយផង ហេតុនោះគេទើបលេងតែក្នុងរឿងកមកេរ្តិ៍ដែល ។ ត្រប់ពះដែលលេង តែបើទុកជាមានលេងជាប្រក្រតី ក៏គង់មិនមាន មនុស្សមើលដូចល្ខោន ព្រោះភាពស្បែកនោះមិនសូវមានសេជាតិជាទី ល្អមើលដូចល្ខោន មិនមានសម្ផស្សប៉ិត្តសម្ផស្សក្រែកដូចល្ខោន ណាដែល មានលេងម្តងៗ នោះច្រើនតែមនុស្សជាន់ទាបទីកូនក្មេងឈរមើល ។ ណាដែលមានលេងម្តងៗនោះ ដោយអ្នកម្ចាស់បុណ្យជួលជាប់ថ្លៃយកទៅ លេងឲ្យគេឲ្យមើល ទើបមានមនុស្សមើលច្រើនៗ បើសិនបើយកថ្លៃពីអ្នក មើល មើលទៅគង់ជាមិនមានអ្នកមើលប៉ុន្មាននាក់ណាស់ ។

## វិធីធ្វើភាពស្បែក

វិធីដែលនឹងធ្វើភាពស្បែកនោះ គេយកស្បែកគោមកត្រាំទឹកឲ្យទន់ ហើយ យកទៅហាលថ្ងៃឲ្យស្ងួត រួចយកដែកមានមុខមុតមកគោសពាំងសងខាង ឲ្យស្តើងទីងឲ្យពបស្មើសាប់ ទើបយកទឹកខ្មៅដែលលាយដោយ ធ្យូងបាតឆ្នាំង ឬ ធ្យូងជាងដូងចុតលាយនឹងទឹកហើយយកមកលាបស្បែក នោះឲ្យសព្វទាំងសងខាង ប្រមាណមើលខ្មៅល្អហើយ យកទៅហាល ថ្ងៃឲ្យស្ងួត កាលស្ងួតហើយគេខាត់ឲ្យរលើបល្អហើយ បើមិនចេះគូររូប ខ្លួនឯង គេរកជាងដែលចេះគូររូបល្អៗ មកគូរជារូបផ្សេងៗ តាមរឿង នោះ គូរហើយត្រួតមើលសព្វគ្រប់ ឃើញថាមិនខុសហើយ ទើបជាប់

ឆ្លាក់ជាយផែតគ្រឿងឆ្លាក់ស៊ីងមានមុខងឹងសណ្ឋានផ្សេងៗ មានពន្លាត ងឹងផែកក្របកជាដើម ។ កាលឆ្លាក់បានប្រិនផ្ទាំងល្មមលេងបានហើយ គេទើបជ្រលក់ ឬ គោសកែឲ្យមានពណ៌ផ្សេងៗ តាមដែលត្រូវការ គឺ បើត្រូវការពណ៌ស ឲ្យកោសល្បប់ខ្មៅដែលលាបនោះចេញឲ្យអស់ហើយ ក៏នៅជាពណ៌ស បើចង់ឲ្យមានពណ៌ខៀវ ឲ្យយកចុណ្ណផុះលាយទឹង ទឹកផ្លែក្រូចឆ្មា លាបទៅក៏ជាពណ៌ខៀវ, បើចង់ឲ្យមានពណ៌ក្រហម ឲ្យយកទឹកស្លែងនឹងសាច់ផ្ទូរលាយគ្នាលាប ក៏ជាពណ៌ក្រហម, បើចង់ ឲ្យមានពណ៌លឿង ឲ្យយកទឹកស្លែងលាយនឹងទឹកក្រូចឆ្មាលាបផុះៗ ទៅក៏ជាពណ៌លឿង ។ កាលជ្រលក់ពណ៌ដូច្នេះស្រេចហើយ ទើប យកឈើបួនចំរៀកមកគាបសងខាង ធ្វើជាមេសម្រាប់កាន់ដើរទៅមក ពល់ៗ រូបនោះទៅ ។

ភាពស្បែកដែលឆ្លាក់ជារូបហើយនោះ មានបញ្ញត្តិឈ្មោះហៅ ផ្សេងៗ គឺភាពដែលជារូបដើរ មិនថាមនុស្សយក្ខ ឬ ស្វា ហៅថា "ភាពបទបរ" ទាំងអស់ ។ ភាពដែលជារូបហោះហើរ មិនថា មនុស្ស យក្ខ ឬ ស្វា ហៅថា "ភាពហោះ" ទាំងអស់ ។ ភាពដែលផ្ដុំពលរៀប ពលសម្រាប់ហែស្ដេច ឬលើកទ័ពចេញទៅ មិនថា មនុស្ស យក្ខ ឬ ស្វា ហៅថា "ភាពរេហ៍ពល" ទាំងអស់ (ពួកនេះសៀមហៅថា "ខេន" ។

ក្រៅអំពីនេះមានរូបភាពផ្សេងៗទៀតជាច្រើន សឹងពុំអាចរៀបរាប់ឲ្យសព្វគ្រប់បានៗ

ក៏តែក្នុងរូបអំបាលនោះ មានរូប ៣ ជាសំខាន់ក្នុងរឿងភាពស្បែក គឺរូបព្រះឥសូរ ១ រូបព្រះនារាយណ៍ ១ រូបព្រះឥសី ១ រូបទាំង ៣ នេះ ហៅថា "ភាពស្ដេច" ឬ "ស្បែកស្ដេច" ជាធំជាប្រធានលើរូបទាំងពួងៗ ភាពស្បែកស្ដេចនេះកាលនឹងធ្វើឡើងគេកាន់លំបាកបន្តិច គឺរូបព្រះ ២ អង្គនោះ គេរើសនៅស្បែកគោរ៉ាបដែលត្រូវខ្លាចព្រាយធ្វើមកធ្វើ រូបឥសី គេយកស្បែកខ្លាធំ ឬខ្លាឃ្មុំមកធ្វើ បើបានស្បែកដូចេះមកធ្វើ គេកាន់ថាជារបស់ពូកែសក្ដិសិទ្ធិៗ រូបទាំង ៣ នេះ កាលនឹងធ្វើអ្នកធ្វើត្រូវស្លៀកសពាក់ស ហើយត្រូវប្រញាប់ធ្វើឲ្យដាច់ក្នុងថ្ងៃនោះ កុំឲ្យកន្លងក្រៅបានៗ

## របស់បូជាគ្រូ

កាលនឹងធ្វើរូបទាំង ៣ នេះ គោងរៀបរបស់ជង្គ័យគ្រូតាមទំនៀម គឺបាយស៊ីប៉ាក់ឆាម ១ គូ ក្រយាបួសគឺបាយមហូបចំណីគ្រៀមគ្រស់ដែលមិនលាយដោយគ្រឿងចំអាបមានត្រីសាច់ជាដើម ១ សំពត់នឹងក្បាលជ្រូក ស្មោរ ១ ប្រាក់បីចង្កៀន ៦ បាទៗ របស់អម្បាលនេះកាលបូជាគ្រូរួចហើយត្រូវបានទៅអ្នកគ្រូធ្លាក់ៗ លុះធ្លាក់រួចហើយ គេលាបជា ៣ ពណ៌ផ្សេងគ្នា គឺរូបព្រះឥសូរលាបពណ៌លឿងខ្ចី ឬចំទមាសក៏បាន រូបព្រះ

ការណ៍លាបពណ៌ទៀត ហើយគូរជាក្បាច់របាំតាមគ្រឿងសំលៀកបំពាក់ ឲ្យល្អវិចិត្រជាងរូបតាំងតួង ព្រោះរូបតាំង ៣ នេះជារបស់សំខាន់សំរាប់ចាកមកលេងបើកកេងជាដំបូង ។

## វិធីធ្វើឆាកផ្ទះ

ឆាកសំរាប់ផ្ទះភាពស្បែកនោះធ្វើដោយសំពត់សយ៉ាងស្តើង ហើយសាច់ជ្រាកយ៉ាងមុន គឺយកសំពត់បែបនោះមកកាត់ជាពីរផ្ទាំងដេរភ្ជាប់គ្នា បង់ឲ្យក្បួបប្តុំគប្បីធ្វើទៅតាមត្រូវការ ធ្វើជាផ្ទៃឆាកត្រង់កណ្តាលប ដើម្បីទីងឲ្យផ្ទះពន្លឺឃើញស្បែកនោះច្បាស់ ជាយជុំវិញគេធ្វើដោយសំពត់ជាខបយ៉ាងក្រាស់ ដើម្បីទីងបំបាំងភាពស្បែកនោះ ក្នុងវេលាដែលចេញលេង ដូចយ៉ាងល្ខោនចេញអំពីឆាកល្ខោន រីឯជាយតាំង ៤ នោះគេឃ្ទប់ដោយសំពត់ពណ៌ផ្សេងៗ ឯណាមួយក៏បាន រួចដាក់ខ្សែជាប្រែនសធ្វើតាមជាយនោះសំរាប់ចងត្រដាងដូចយ៉ាងឆាកផ្ទះកុន ឆាកនោះបួនជ្រុងស្មើប្រវែងទំហំ ៧ ហត្ថក៏មាន ៩ ហត្ថក៏មាន ១១ ហត្ថក៏មានស្រេចហើយនូវត្រូវការ ។

## រោងលេងភាពស្បែក

វេលាទីងលេងភាពស្បែកនោះ គេសង់រោងមួយសំរាប់លេងគឺធ្វើជារោងសសរ ៤ ទំហំធំតូចធ្វើតាមឆាកផ្ទះដែលពោលហើយ មានផ្ទៃខ្ពស់ឡើងពីដីប្រមាណស្មើក្បាលមនុស្ស ដំបូលប្រក់ស្លឹកបញ្ឆៀងទាំង ដូច

យ៉ាងបង្ហា ហើយបិទទាំងជញ្ជាំងទាំង ៣ ជ្រុង ទុកតែខាងមុខឲ្យនៅកល សំពត់បង់ធាកផ្ទះនៅក្នុងសសរទាំង ៤ ដោតទង់ប្រដាប់ឲ្យជាទីល្អមើលផង ។

## វិធីលេងភាពស្បែក

ភាពស្បែកនេះគេលេងតែវេលាយប់ ព្រោះត្រូវការពន្លឺភ្លើងឆ្លុះរូប វេលារសៀលជិតដល់ពេលនឹងលេង គេក៏ដញ្ជូនភាពស្បែកធាកផ្ទះនិងគ្រឿងភ្លេងទៅរៀបដាក់ក្នុងរោងនោះឲ្យហើយស្រេចពីវេលាថ្ងៃ ។ ដល់វេលាព្រលប់ពួកអ្នកលេងទាំងប៉ុន្មាន គឺអ្នកដើតអ្នកបរោហិតគ្រូគង់និងពួកភ្លេងពិណពាទ្យក៏ទៅប្រជុំគ្នានៅរោងនោះដើម្បីលេង ខណៈនោះម្ចាស់បុណ្យគេយកទៀន ៣ ដើមនឹងប្រាក់ ៣ ស្លឹងជារបស់កំណត់ត្រូវទៅឲ្យម្ចាស់ភាពស្បែក ។ យកទៀន ១ ដើមចែកឲ្យទៅពិណពាទ្យ ពួកពិណពាទ្យទទួលយកទៀននោះមកអុជនៅសំភោ ហើយនាំគ្នាលេងភ្លេងហោមរោង ។ នោះតាំងភ្លេងសាធុការឡើងជាដំបូង ហើយភ្លេងប្រះ, ឬហៅថាត្រះពេទ ៣ បទ បូលកុង លាស្មើ ជា ៦ ភ្លេងផងគ្នា រួចហើយពិណពាទ្យក៏ឈប់ អ្នកបរោហិតយកទៀនអុជបូជានៅភាពស្បែក ស្មូតទាំងពីរគន្ថ, បំណែកឯមនុស្សទាំងពួងក្នុងពួកនោះក៏ហោឡើង ៣ ដង អ្នកដើតក៏លើករូបព្រះឥសូរឡើងដើត ពួកអ្នកភ្លេងក៏លេងភ្លេងដើតតទៅ លំដាប់នោះអ្នកបរោហិតអុជទៀនបូជា ហើយក៏ថយទៅឈរនៅទីរបស់ខ្លួន ហើយលើក

ដៃឃាត់ពិណពាទ្យឲ្យឈប់ អ្នកបរោហិតពោលបទនមស្សការព្រះជាម្ចាស់ ៣ បទតាមទំនៀម ។

វេលាចប់បទទី ១ ហើយពួកពិណពាទ្យក៏លេងភ្លេងដើតទៀត អ្នកបរោហិតក៏លើកដៃឃាត់ភ្លេង ហើយពោលបទទី ២ តទៅ លុះចប់ហើយ អ្នកភ្លេងក៏លេងភ្លេងដើតទៀត អ្នកបរោហិតក៏លើកដៃឃាត់ភ្លេង ហើយក៏ពោលបទទី ៣ តទៅ ចប់ហើយអ្នកភ្លេងក៏លេងភ្លេងដើតដូចមុន ។

លំដាប់នោះអ្នកគ្រាបន្ទុះក៏យកបន្ទុះ ៣ ដើមមកអុជបន្ថិលជុំវិញជើងបន្ទុះ (គឺទីសម្រាប់ដុតបន្ទុះ) ៣ ជុំហើយ យកភ្លើងបន្ទុះនោះទៅអុជអាចម៍បន្ទុះ ដែលគេទុកនោះ ភ្លើងក៏ឆេះផ្ទាលឡើង ពួកពិណពាទ្យក៏លេងភ្លេងដើតឡើងព្រមគ្នា ចំណែកឯអ្នកបរោហិតក៏ចេញមកលត់ទៀនដែលបូជាស្បែក ហើយក៏ធ្វើពិធីឧមអាមសេពសំមន្តអាគមតាមទំនៀមដែលគេរៀនសូត្រមក អ្នកដើតក៏យកកាពស្បែកមកផ្ទុះម្តងទៀត ប៉ុណ្ណោះឈ្មោះថាចប់ពិធីហុមរោងបើកមុខព្រះហើយ ។

លុះហុមរោងបើកមុខស្រេចហើយ លំដាប់នោះគេច្រៀនចាប់លេងរឿងស្វាប្រចាប់គ្នា គេបញ្ចេញរូបស្វាស ១ ស្វាខ្មៅ ១ លើកដើតចេញមកពីខាងឆ្វេង ១ ពីខាងស្តាំ ១ មកប្រចាប់គ្នាកណ្តាលទី វេលានោះពួកភ្លេងក៏លេងភ្លេងដើត តែត្រូវផ្លុំតែស្រឡៃ ១ គងធំរនាតឈប់បន្តិចសិន ចំណែកឯស្គរធំគេត្រូវវាយឲ្យឮខ្លាំងឡើងដែលហៅថាដើត

ណក គឺដើរចេញក្រៅ ស្វាទាំង ២ នោះប្រតាប់គ្នា មួយស្របក់ ហើយក៏លែងគ្នាចេញទៅដោយសព្វខ្លួន រួចត្រឡប់ដើរចូលមកតាប់គ្នាទៀតជាការៈទី ២ និងការៈទី ៣ ដូចការៈទី ១ ភ្លេងក៏លេងដូចគ្នានឹងការៈទី ១ ដែរ ត្រង់នេះហៅដោយឈ្មោះថា ស្វាប្រតាប់ការៈទី ១ ស្វាប្រតាប់ការៈទី ២ ស្វាប្រតាប់ការៈទី ៣ ក្នុងខណៈការៈប្រតាប់គ្នាទី ៣ នោះ គេក៏ដើររូបស្វាស បងស្វាខ្មៅនឹងដើររូបឥសីចេញមក ពួកភ្លេងក៏លេងភ្លេងដើរហើយឈប់ សន្មតថាស្វាសឈ្នះស្វាខ្មៅ ចាប់បងស្វាខ្មៅបាននាំយកមក លុះមកដល់ទីឥសីៗ ក៏សុំឲ្យលែង ដល់មកត្រង់នេះ អ្នកបរោតក៏ចេញមកបរោតការមារឿងតែត្រូវធ្វើសំឡេងថៃឡាំ បែបយ៉ាងអ្នកស្រុកក្រៅដែលនិយាយមិនច្បាស់ លុះបរោតចប់រឿងហើយ ក៏ដើរត្រឡប់ទៅវិញ ។

តែជួនកាលគេមិនលេងរឿងស្វាប្រតាប់គ្នានេះ គេចាប់លេងរឿងនាងមេខលា ដែលគេទុកជារឿងចាប់ប៉ាំខាងដើមរឿងដែលមិនលេងនោះៗ គឺដើររូបនាងមេខលា រាមសូរអរជុនចេញមក ពួកភ្លេងក៏លេងភ្លេងដើរតាមនោះ ។

កាលលេងចប់បទហោមរោង ទើបរបាំបើករោងស្រេចដូច្នេះហើយ គេក៏ចាប់លេងសាច់រឿងទៅ តាមប្រក្រតីច្រើនលេងរឿងរាមកេរ្តិ៍ខាង

ដើម ត្រង់ខ - ខូសណ៍ទីង ព្រះលក្ខណ៍ពង្រាំងគ្នា ព្រោះរៀងនាងស្ទះ-ជនោ ជាដើម ។

ចំណែកឯក្មេងដែលលេងនោះ គេលេងតាមក្មេងល្មោនធម្មតាដូចមានពោលហើយក្នុងរឿងល្មោន ។

## គ្រឿងភ្លេង

ឯគ្រឿងភ្លេងសម្រាប់លេងភាពស្បែកនេះ គេលេងតែវង់តូច តិសក្តេ ១ ស្គរធំ ១ រនាត ១ វង់ គង ១ វង់ សាឡៃ ១ ឈឹង ១ ។ ព្រោះភាពស្បែកនេះគេទុកជាតូចជាងល្មោន ទើបចាត់គ្រឿងភ្លេងឲ្យមានតិច តែល្មមសមគួរ ។

ឃុនសុន្ទរមេធ ញ៉ុង-សៀង ប្រែ

លោកហង់-ធីមសេង ពិនិត្យ

# រឿងនូរេនឌិន-អលី និង បេទ្រេទឌិន-ហស្ស៊ែន

(តមក)

---

លុះសរសេរសំបុត្ររួចហើយ បេទ្រេទឌិន-ហស្ស៊ែន ក៏ហុចទៅឲ្យថៅកែគុំសាក់ឌ ៗ បានទទួលយកមកខ្ចប់ក្នុងប្រអប់ សម្រាប់ដាក់សំបុត្រស្នាមផ្សេងៗ ហើយជំរាបលាបេទ្រេទឌិន-ហស្ស៊ែន ដើរចេញអំពីទីនោះសំដៅចូលទៅកាន់ទីក្រុងយ៉ាងប្រញាប់ប្រញាល់ ព្រោះពេលកាន់តែជិតយប់ហើយ ។ ចំណែកខាងបេទ្រេទឌិន-ហស្ស៊ែន ដើរសំដៅទៅរកផ្នូរនូរេនឌិន-អលី ជាបិតារបស់ខ្លួន; លុះបានទៅដល់ទីនោះហើយ ទើបលុតជង្គង់សំពះឱនក្បាលរាបទៅនឹងដី សំដែងសេចក្តីគោរពយ៉ាងស្មោះអស់ពីពោះ, មានមុខទាំងមូលទទឹកជោគទៅដោយទឹកភ្នែក ហើយក៏តាំងយំខ្សឹកខ្សួលអួលអន់ដង្ហក់ ទ្រូញត្អូញត្អែរអំពីសេចក្តីទុក្ខវេទនារបស់ខ្លួនថាដូច្នេះ "ឱ! បេទ្រេទឌិនកំសត់! អ្នកឯងនឹងទៅជាមនុស្សយ៉ាងណាទៅ? អ្នកឯងនឹងទៅរកទីពឹងពំនាក់ក្នុងទីណា ដើម្បីនឹងតក់ចំពោះសេចក្តីទុក្ខធំដែលព្រាប់ព្រាត់អ្នកយ៉ាងនេះ ? ឱអនិច្ចាកម្មអើយ កើតទុក្ខសង្រេងសង្រែងអំពីមរណភាពនៃបិតាសំឡាញ់ មិន

ទាន់បានស្រែកស្រាន្តប្ដូរស្បើយផង ស្រាប់តែមានគ្រោះថ្នាក់មកជះជាន់កថែមទៀត! ឱរូបអើយរូប! កម្មកោសអ្វីក៏ខុសគេខ្លាំងម្ល៉េះ!'' ។ បេទ្រេទឌិនហស៊្យន ក្រាបពោបទៅនឹងដីហើយយំសោកយ៉ាងនេះអស់ពេលជាយូរណាស់ ទើបក្រោកឡើងវិញ ហើយដាក់ក្បាលផ្អឹបទៅនឹងផ្ទះខ្មោចផុត, សេចក្ដីទុក្ខសោកខ្សឹកខ្សួលទន្ទិះគាបគ័ងក្នុងទ្រូងក៏រឹងរឹតតែទ្រុតថែមឡើងទៀតយ៉ាងពីមុន, បេះដូងស្ទើរផ្ទុះដោយអណ្ដឹកអណ្ដករហូតទាល់តែខ្យល់ទ្បាំងបត្តិបម្លង ។ ទើបរំកិលងាកក្បាលអំពីផ្ទះ ហើយប្រះខ្លួនសន្ទឹងដេកលក់ស្លុកស្ដឹងលើគ្រោលឥដ្ឋកៀនផ្នូរនោះទៅ ។

ក្នុងគ្រាដែលមាណពបេទ្រេទឌិនហស៊្យន កំពុងលក់សិប់យ៉ាងនេះស្រាប់តែមានបិសាចមួយដែលធ្លាប់នៅអាស្រ័យក្នុងទីសុសាននោះក្នុងពេលថ្ងៃ ហើយចេញដើរត្រាច់រង្គាត់ក្នុងពិភពលោកក្នុងពេលយប់ៗតាមទំនៀមធម្មតា, បានប្រទះឃើញមាណពកំពុងដេកលក់ក្បែរផ្នូរនៃខុនអលីផ្លូបោះ ក៏ចូលទៅជិតដើម្បីសង្កេតមើលឲ្យជាក់ច្បាស់; ដោយពេលនោះ មាណពបេទ្រេទឌិនហស៊្យនដេកផ្ងារ ទើបលំអទ្រង់ទ្រាយមុខមាត់ទាំងមូលក្ដីស្រស់បំព្រង ហាក់ដូចជាបែងចាំងដល់ចក្ខុរបស់បិសាច ។

កាលបិសាចពិនិត្យសង្កេតមើលជាក់លាក់ហើយ ក៏លោលាន់មាត់តែម្នាក់ឯងថា ''អើហ្ន៎! មាណពនេះបើតាមសង្កេតមើលរូបពង្សមុខមាត់

ដែលល្អស្រស់ប្រិមដូច្នេះ មិនមែនជាអ្នកឋានផែនដីទេ គឺជាទេព្ធាមួយអង្គក្នុងឋានសួគ៌ ដែលព្រះបានចាត់មកឲ្យកើតក្នុងមនុស្សលោកនេះដោយពិត" ។ លុះនិយាយដូច្នេះហើយ ទើបបិសាចនោះហោះហើរទៅលើអាកាស បានឧបួបនឹងនាងទេពធីតាម្នាក់ ហើយក៏ដាក់ប្រស្នាទៅវិញទៅមកដោយសេចក្តីគួរសម ។ រួចហើយ បិសាចនិយាយទៅកាន់នាងទេពធីតាថា "សូមនាងចុះទៅជាមួយនឹងខ្ញុំ ទៅរហូតដល់ទីស្ថាន ដែលខ្ញុំធ្លាប់នៅអាស្រ័យនោះ ខ្ញុំនឹងបង្ហាញរបស់មួយដ៏គួរកាលប៉ីឡែកអស្ចារ្យ, បើនាងបានឃើញហើយ មុខជានឹងកោតសរសើរដូចខ្ញុំពុំខាន" ។ នាងទេពធីតាក៏យល់ព្រមតាមហើយ ទើបចុះអំពីអាកាសមកជាមួយនឹងពីរនាក់ក្នុងខណៈនោះភ្លាម; កាលបានមកដល់ក្នុងផ្ទះនោះហើយ បិសាចបង្ហាញបង្ហាញថា " នាងធ្លាប់បានឃើញកំឡោះណាមួយល្អលើកជាងមាណពនេះទៅទៀតដែរឬ ? " ។

នាងទេពធីតា បានសង្កេតពិនិត្យមើលបោទ្រទ្រខ្ញុំនហស្សនដោយម៉ត់ចត់ហើយ ក៏ងាកមកនិយាយនឹងបិសាចវិញថា ' មាណពនេះមានរូបល្អស្រស់មែនហើយ, ប៉ុន្តែមានរបស់មួយលើកគួរកាលជាងនេះទៅទៀតដែលខ្ញុំទើបនឹងឃើញអម្បាញ់មិញនៅឯក្រុងកៃរ៉ូឯណោះ, បើអ្នកបង់ស្តាប់ខ្ញុំនឹងនិយាយរឿងប្រាប់ឥឡូវនេះ" ។ បិសាចឆ្លើយឡើងថា "បាទ, ល្អហើយ សូមនាងនិយាយចុះ" ។ នាងទេពធីតា ប្រាប់បិសាចឲ្យ

ប្រឹងស្តាប់ដោយយកចិត្តទុកដាក់មែនទែន ព្រោះនាងចាប់យករឿងនោះ មកនិយាយពីចម្ងាយ ហើយគង់ប្រាយកយសេចក្តីថា "ព្រះរាជាប្រទេសអេស៊ីប្ទមានអគ្គមហាសេនាម្នាក់ឈ្មោះ សេមសេទឌិន ម៉ូហាម៉េទ ហើយលោកសេនាបតីនេះមានកូនក្រមុំអាយុប្រហែល ២០ ឆ្នាំ ។ នាងនោះមានរូបឆោមលោមព័ណ៌ យ៉ាងឆើតឆាស្រីគ្រប់ល័ក្ខណ៍ ដែលមិនធ្លាប់ឮអ្នកណាមួយនិយាយម្តងសោះ ។ ព្រះរាជាប្រទេសអេស៊ីប្ត បានជ្រាបដំណឹងថាកូនក្រមុំលោកអគ្គមហាសេនា មានរូបល្អណាស់ទំនងរកស្រីឯណាមកប្រដូចគ្មាន ទើបទ្រង់ត្រាស់ឲ្យហៅអគ្គមហាសេនានោះមកហើយទ្រង់មានបន្ទូលថា "អើលោកអគ្គមហាសេនា, ខ្ញុំបានដំណឹងថាលោកមានកូនក្រមុំមួយមានអាយុគ្រប់ការហើយ ឥឡូវនេះខ្ញុំចង់សុំយកមកធ្វើជាស្រីស្នំ, រឿងនេះតើលោកយល់ព្រមឲ្យខ្ញុំឬមិនព្រម? អគ្គ-មហាសេនាឥតមានបានគិតគូរដឹងរឿងការនេះពីមុនសោះ ស្រាប់តែមកឮព្រះឱង្ការដូច្នោះ ក៏ស្រឡាំងកាំងភាំងស្មារតី; ប្រសិនបើរូបអ្នកដទៃក្រៅពីព្រះរាជាវិញនោះ សមបើលោកអគ្គមហាសេនាទំព្រមទទួលដោយសេចក្តីត្រេកអរណាស់ ប៉ុន្តែមកប៉ះលើព្រះរាជាដូច្នេះលោកមិនបានរីករាយសប្បាយចិត្តទេ ទើបក្រាបបង្គំទូលថា "បពិត្រព្រះករុណាជាម្ចាស់ជីវិតលើត្បូង, សូមទ្រង់ព្រះមេត្តាប្រោស; ទូលបង្គំសូមគួរដល់ព្រះកិត្តិយស ដែលព្រះអង្គទ្រង់មានព្រះរាជបំណងចង់ស្ពាន

មេត្រីចំពោះរូបទូលបង្គំទេ, រឿងនេះ ទូលបង្គំសូមក្រាបក្រោមល្អងធូលី ព្រះបាទ សូមអង្វរកុំឲ្យទ្រង់មានព្រះចិន្តាយល់ឃើញថា ទូលបង្គំជាមនុស្សកាក្រក់ ព្រោះតែទទឹងទាស់នឹងព្រះរាជអធ្យាស្រ័យឡើយ ។ ព្រះអង្គទ្រង់បានជ្រាបស្រាប់ហើយថា ទូលបង្គំមានកូនប្រុសមួយឈ្មោះ នូរេទ-ឌិន-អលី ដែលបានទទួលតំណែងយសសក្តិជាអគ្គមហាសេនារបស់ទ្រង់ដូចជារូបទូលបង្គំដូច្នេះដែរ; យើងមានសេចក្តីទាស់ទែងខ្វែងគំនិតគ្នា ដែលជាហេតុនាំបណ្តាលឲ្យប្អូននោះតែចោលស្រុកបាត់ទៅ ហើយតាំងពីពេលនោះមក ទូលបង្គំមិនដែលបានដឹងដំណឹងដំណួបអ្វីសោះ, ទើបតែក្នុងរវាង ៤ ថ្ងៃមុននេះ ទូលបង្គំបានឮដំណឹងថា ប្អូននោះធ្វើមរណកាលទៅ ហើយនៅឯក្រុងបាល់សូរ៉ាឯណោះ នៅក្នុងឋានន្តរជាអគ្គមហាសេនានៃព្រះរាជាក្នុងក្រុងនោះឯង ។ ប្អូនទូលបង្គំនោះមានកូនប្រុសមួយ ហើយយើងបានសន្យាគ្នាតាំងពីរនាក់តាំងពីពេលមុនថា បើមានកូនយើងនឹងធ្វើផ្សំគ្នា, ទូលបង្គំជឿជាក់ប្រាកដថាសូម្យ៉ាកធ្វើមរណកាលទៅយ៉ាងនេះ ក៏គង់មានបំណងចង់ឲ្យទូលបង្គំធ្វើតាមពាក្យពិភាក្សានោះកុំខាន; ព្រោះហេតុនោះ តាមបំណងរបស់ទូលបង្គំ គឺចង់បំពេញសេចក្តីប្តេជ្ញានោះឲ្យបានពេញលេញកុំឲ្យល្អៀងឃ្លៀងឃ្លាត, ទូលបង្គំសូមអង្វរព្រះរាជហឫទ័យ សូមទ្រង់មេត្តាប្រោសប្រណីអនុញ្ញាតឲ្យបាន; នៅ

ក្នុងក្រុងនេះ ពួកនាហ្មឺនសព្វមុខមន្ត្រីដែលមានកូនក្រមុំដូចជាទូលបង្គំនេះ ក៏មានច្រើនគ្នា ហើយល្មមព្រះអង្គយកមកធ្វើជាស្រីស្នំបាន" ។

ព្រះរាជាប្រទេសកោសម្ពី កាលបានព្រះសណ្ដាប់ពាក្យនេះហើយ ក៏ទ្រង់ព្រះពិរោធយ៉ាងខ្លាំងចំពោះសេនាសេនខិនមហាម្ចេ ។

ដោយទ្រង់ខ្ញាល់ខ្លាំងនឹងលោកឧត្តមមហាសេនាដែលទទឹងទទែងស្រហើនប្រកែកជួបេះ ទើបទ្រង់មិនអាចទប់ទល់សេចក្ដីក្រោធបាន ហើយក៏មានព្រះឧង្កាត្រៃតោះហោះហោកតំហាតកំហែងថា « អ្នកឯងហៅគេញជាចក្ដុមែន ប្រហែលជុនយើង អ្នកឯងហ៊ានមើលងាយថាមិនសមគួរនឹងបងញាតិគ្នាជាមួយនឹងអ្នកឯងឬ? អ្នកឯងហ៊ានលើកទុកលើកដាក់បង្គាប់ឲ្យយើងរកកូនក្រមុំអ្នកឯងទៀតវិញ; រឿងនេះមិនអីទេ, អ្នកឯងចាំមើលចុះ យើងនឹងសងសឹកឲ្យអ្នកឯងជិនខ្លួនមួង; យើងសន្យាថា កូនក្រមុំអ្នកឯងគតបានប្ដីដទៃក្រៅពីខ្ញុំដ៏ជាយើងដែលជាមនុស្សថោកល្ងង់ជាតិហើយមានរូបអាក្រក់ក្រណាចនិងអាក្រក់នោះឡើយ ។ កាលមានព្រះឧង្កាជួបេះហើយ ទ្រង់បណ្ដេញអគ្គមហាសេនាឲ្យចេញសចេញជាប្រញាប់, លោកអគ្គមហាសេនាក៏ថយខ្លួនទៅកាន់ផ្ទះ ដោយមានសេចក្ដីខានគានគិតបិត្តនឹងសេចក្ដីតាមសម្រុះជាទីបំផុត ។ ក្នុងថ្ងៃនោះ ស្ដេចទ្រង់ត្រាស់ប្រើឲ្យហៅនគ្គាលសេះម្នាក់របស់ព្រះអង្គឲ្យចូលមកគាល់ ដើម្បីនឹងផ្សុំផ្ទុំឲ្យជាប្ដីនានក្រមុំកូនអគ្គមហាសេនា, ឯបុរសនោះគមទាំងមុខគម

ទាំងក្រោយ ហើយរូបកាងអាក្រក់ខ្មៅក្រញាសទាបក្រញ៉ុញ មុខរ៉ីញ ប្រែខ្ញុញដូចខ្មោចលង មើលទៅគួរឲ្យខ្លាច, លុះទ្រង់បានតាំងការជ្រាបជាក់ កំរិតឲ្យអគ្គមហាសេនា សមសេទឌីន ម៉ូហាម្មេទយល់ព្រមរៀបចំធ្វើមង្គល ការគូទក្រមុំខ្លួនជាមួយខ្ទីងបុរសគមនោះរួចហើយ ទើបទ្រង់ឲ្យទៅធ្វើ សំបុត្រលក្ខិកសញ្ញាអាពាហ៍ពិពាហ៍ រួចឲ្យសាក្សីជាច្រើនរូបចុះហត្ថ-លេខាសម្រេចកូនទីចំពោះព្រះភក្ត្រព្រះអង្គ ។ ឥឡូវនេះ អាពាហ៍ពិពាហ៍ជាអពមង្គលនោះ គេបានរៀបចំរួចហើយ; ពេលដែលខ្ញុំកំពុងនិយាយប្រាប់អ្នកនេះ ពួកបារ៉ែរបស់នាងកើនមុខមន្ត្រី កូនកជ-ត្រកូលប្រទេសអេស៊ីប្តីបានមកជួបជុំគ្នានៅក្បែរទ្វារបន្ទប់ទឹកមួយ កាន់ទៀនកាល់តែដៃគ្រប់ៗគ្នា រង់ចាំតែបុរសគមជូតទឹកសំអាតខ្លួនប្រាណរួច ទីងកាលនាំយកទៅឯផ្ទះប្រពន្ធ ដែលបានស្អិតស្អាងតាក់តែងខ្លួនរួចជាស្រេច ។ កូនពេលដែលខ្ញុំចេញពីក្រុងកែមកអម្បាញ់មិញនេះពួកស្រីបានមកជួបជុំគ្នាអស់ហើយ កំពុងរៀបចំទីងនាំនាងក្រមុំនោះព្រមទាំងគ្រឿងប្រដាប់សម្រាប់អាពាហ៍ពិពាហ៍ ទៅដាក់កូនបន្ទប់មួយបំរុងរង់ចាំទទួលបុរសគមជាប្តី ។ ខ្ញុំបានឃើញជាក់លាក់ហើយ, ខ្ញុំហ៊ានសន្យាតាំងភាល់ទីងអ្នកឯងថា គេមិនអាចពិតពិលមើលរូបនាងក្រមុំនោះដោយឥតសេចក្តីស្ញើបសរសើរឡើយ ។

កាលនាងទេពធីតាបញ្ចប់ពាក្យនេះហើយ, បិសាចក៏ចាប់និយាយថា "ទោះបីនាងនិយាយអួតសរសើរយ៉ាងនេះ ក៏ខ្ញុំនៅតែមិនទាន់ជឿសិនថា នាងនោះមានរូបឆោមល្អជាងអ្នកកំលោះនេះ" ។ នាងទេពធីតាតបថា "ខ្ញុំមិនត្រូវការជជែកគ្នាជាមួយនឹងអ្នកតទៅទៀតទេ, ខ្ញុំប្រាប់អ្នកឲ្យត្រង់ថាអ្នកកំលោះនេះ បើយកទៅផ្សំផ្គុំនឹងនាងក្រមុំព្រហ្មចារីនី ដែលគេបំរុងនឹងទុកឲ្យបុរសគមនោះ ឃើញថាសមគ្នាណាស់; ខ្ញុំគិតឃើញឧបាយមួយ ដែលខាមចំនងល្មមយើងធ្វើបាន ដើម្បីនឹងជំទាស់ផ្ចាញ់ផ្ចាលដល់អយុត្តិធម៌របស់ស្តេចប្រទេសអេស៊ីប, ឧបាយនោះគឺយើងយកអ្នកកំលោះនេះទៅដាក់ប្តូរជំនួសអាគមគន្លាលសេះនោះឯង" ។ បិសាចឆ្លើយទទួលព្រមថា «ឧបាយដែលនាងគិតនេះប្រពៃហើយ, ខ្ញុំយល់ព្រមតាមទាំងអស់, យើងនឹងបំភ័ន្តសេចក្តីសង្ឃឹមរបស់ស្តេចប្រទេសអេស៊ីប ហើយយើងលួងលោមឪពុកដែលកំពុងកើតទុក្ខឲ្យបានធូរទ្រូង ព្រមទាំងធ្វើកូនក្រមុំគាត់ដែលស្មានថាមុខជានឹងធ្លាក់ខ្លួនថុនជាប់ថោកទាបនោះឲ្យបានសប្បាយរីករាយឡើងវិញ ។ ខ្ញុំនឹងធ្វើឧបាយនេះឲ្យសម្រេចឥឡូវនេះពុំខាន ហើយខ្ញុំសង្ឃឹមទុកចិត្តថា នាងក៏គង់មិនបដិសេធនឹងរឿងនេះដែរ; ខ្ញុំហ៊ានធានាក៏ប៉ះបើបតយកអ្នកកំលោះនេះទៅដាក់ឯត្រង់ដែលនាងកំពុងដេកលក់យ៉ាងនេះ កុំឲ្យភ្ញាក់ដឹងខ្លួនសោះ ហើយកាលបើយើងធ្វើកិច្ចនោះសម្រេចសព្វគ្រប់ដូចបំណងហើយ គាត់:

ដែលនឹងលើកតពួកកំឡោះនេះទៅដាក់ក្នុងទីដទៃទៀតនោះ ខ្ញុំសូមប្រគល់លើនាង ។

លុះនាងទេពធីតានឹងបិសាច ពិភាក្សាជាមួយគ្នាអំពីកិច្ចដែលបំរុងនឹងធ្វើនោះរួចហើយ ទើបបិសាចលើកត្រកងបីបេទ្រេឌិន-ហាស្សែនថ្នមសន្សើម ៗ កុំឲ្យភ្ញាក់ហើយក៏ហោះឡើងទៅកាន់អាកាសយ៉ាងរហ័សដែលផុតវិស័យមិនអាចនិយាយបាន, យកទៅដាក់ត្រង់ទ្វារផ្ទះមួយជិតបន្ទប់ទឹកដែលបុរសគម្លួតទឹករួចហើយរៀបនឹងចេញមក, ខានទាំងពួកបាវព្រាវជាច្រើននាក់ រង់ចាំបំរុងហែហាមជូនដំណើរផង ។

ក្នុងខណៈនោះ បេទ្រេឌិន ហាស្សែន ភ្ញាក់ឡើងស្រាប់តែស្រឡាំងកាំងភាន់ភាំងស្មារតី ព្រោះឃើញខ្លួនឯងនៅកណ្ដាលទីក្រុងដែលខ្លួនឥតស្គាល់សោះ, រៀបនឹងហាមាត់ស្រែកសួរគេថា ហេតុដូចម្ដេចក៏មកនៅក្នុងទីនេះដូច្នេះ, ប៉ុន្តែបិសាចទះស្មាហើយខ្សឹបប្រាប់ថា កុំមាត់ ៗ នៅឲ្យស្ងៀម; តទៅទៀត, បិសាចបានឲ្យទៀនមួយទៅបេទ្រេឌិន-ហាស្សែនហើយក៏ប្រាប់ថា "ទៅ, ចូរអ្នកដើរបន្តក្នុងចំណោមមនុស្សដែលអ្នកឃើញក្បែរទ្វារបន្ទប់ទឹកនោះ ហើយចូរដើរតាមគេទៅរហូតទាល់តែដល់បន្ទប់មួយ ដែលគេកំពុងរៀបចំធ្វើមង្គលការ ទាំងខ្លួនអ្នកក៏ត្រូវតែចូលតាមទៅក្នុងបន្ទប់នោះដែរ ។ ឯប្ដីថ្មី អ្នកនឹងអាចស្គាល់បានដោយងាយណាស់ ព្រោះវាគខ្ពស់ពីគេទាំងអស់, កាលចូលទៅអ្នកត្រូវដើរកែប

ខានស្ដាំក, ហើយត្រូវបើកថង់ប្រាក់ដែលមាននៅជាប់នឹងខ្លួន យកប្រាក់ដើរចែកឲ្យពួកអ្នកភ្លេង និងពួករបាំប្រុសស្រីទាំងអម្បាលម៉ាន ។ វេលាដែលអ្នកចូលទៅដល់ក្នុងបន្ទប់នោះហើយ, អ្នកកុំភ្លេចឲ្យសោះ គឺត្រូវយកប្រាក់ពីក្នុងថង់ហុចឲ្យពួកស្រី ៗ ជាអ្នកបំរើផង ដែលអ្នកនឹងឃើញនៅកំដរជុំវិញសាមីខ្លួនប្រពន្ធ កាលបើស្រីបំរើទាំងនោះចូលមកជិតអ្នក ៗ ប៉ុន្តែរាល់តែគ្រា ដែលអ្នកលូកដៃទៅក្នុងថង់នោះ, អ្នកត្រូវក្រសោបយកប្រាក់ឲ្យពេញដៃ ហើយត្រូវសំចៃកុំឲ្យអស់ ៗ អ្នកត្រូវធ្វើឲ្យប្រាកដ តាមពាក្យដែលខ្ញុំនិយាយប្រាប់នេះ ដោយការតាំងស្មារតីឲ្យរឹងប៉ឹងមាំ, កុំភិតភ័យ, កុំតក់ស្លុតឲ្យសោះ រួចហើយចូរអ្នកទៅសម្រាកជាមួយនឹងស្រីកញ្ញាដែលនៅសម្រាកក្នុងបន្ទប់នោះឯង ៗ

អ្នកកំឡោះបេទ្រឌិន បានយល់ជាក់ច្បាស់អំពីឧបាយដែលខ្លួនត្រូវធ្វើនោះហើយ ក៏ចូលទៅក្បែរទ្វារបន្ទប់ទឹក; កិច្ចជាដំបូង ដែលបេទ្រឌិនត្រូវធ្វើនោះ ក៏គឺទៅដល់ភ្លាមតាំងសុំអុជទៀនរបស់ខ្លួនបន្តអំពីបាវម្នាក់ រួចហើយដើរទន្ទឹមជាមួយនឹងមនុស្សឯទៀត ធ្វើខ្លួនហាក់ដូចជាបាវព្រាវរបស់មន្ត្រីណាមួយនៅក្រុងកែវដែរ, ដើរជូនដំណើរបុរសគម ដែលចេញពីបន្ទប់ទឹក ហើយជិះសេះទៅកាន់ផ្ទះខាងស្រី ។

បេទ្រឌិន ហស្ស៊ីន ដើរទន្ទឹមជាមួយអ្នកភ្លេងនិងពួករបាំប្រុសស្រី ដែលដើរនាំមុខបុរសគម ក៏បានលូកយកប្រាក់មួយៗ ពេញទាំងដៃអំពី

ធនិមតែកឲ្យពួកគេប៉ាំ ទាំងនោះ ។ ដោយបេទ្រេទឌិន ហាស្សៀន មាន ចិត្តទូលាយចំណាយប្រាក់កាសតែតវៃតដល់អ្នកផង តែនណាប្រដូច គ្មានហើយមានទឹកមុខញញឹមស្រស់ស្រាយយ៉ាងនេះ ទើបអ្នកដែលបាន ទទួលអំណោយទាំងអម្បាលម៉ាននោះ នាំគ្នាសំឡឹងមើលគ្រប់ ១ គ្នា; កាលបានពិនិត្យសង្កេតមើលហើយ ឃើញថាបេទ្រេទឌិនហាស្សៀនមានរូប សម្បត្តិសក្តិសមល្អដើតជាងមនុស្សទាំងពួង, ពួកទាំងនោះក៏បេះតែសំឡឹង មើលហើយមើលទៀតមិនដាក់ភ្នែក ។

តមក គេបានទៅដល់ទ្វារផ្ទះលោកអគ្គមហាសេនាសេមសេនឌិន ម៉ូហាមេទដែលពុំបានគិតស្មានថា ក្មួយមកដល់ជិតបង្អើយក្បែរខ្លួនលោក យ៉ាងនេះសោះ ។ ពួកព្រះរាជអាជ្ញា ក៏ឃាត់បាវព្រាវទាំងឡាយដែល កាន់ទៀនគ្រប់ដៃមិនឲ្យចូលទៅ ដើម្បីកុំឲ្យពាកពួនជ្រួលច្របល់ ច្រើនពេក ហើយព្រានឃាត់ទាំងបេទ្រេទឌិន ហាស្សៀនផង, ប៉ុន្តែពួកអ្នក ក្មេងទាំងអស់ ឈប់ជជែកតក៏ថាបើមិនបើកឲ្យបេទ្រេទឌិន ហាស្សៀនចូល ទៅជាមួយផងទេ ពួកគេក៏មិនព្រមចូលទៅដែរ, រួចហើយនិយាយតទៅ ទៀតថា "អ្នកកំឡោះនេះមិនមែនជាបាវព្រាវនៅក្នុងស្រុកនេះទេ ត្រូវ ពិនិត្យមើលឲ្យជាក់ច្បាស់ជាមុន គឺជាមនុស្សប្រទេសក្រៅទេតើ គេត្រូវ ការមើលរបៀបបុណ្យអាពាហ៍ពិពាហ៍នៅក្នុងក្រុងយើងនេះ" ។ កាល និយាយដូច្នោះហើយ អ្នកក្មេងទាំងនោះ ទោះបីពួកព្រះរាជអាជ្ញាពកាំង

ដូចម្ដេចក៏មិនព្រមស្លាប់ នាំគ្នាចាប់បេទ្រទឌិន - ហាស្ប៊ែន បញ្ចូលមកក្នុងក្រមខ្លួនហើយឲ្យប៉ូលទៅទាល់តែបាន រួចហូតយកទៀនពីដៃបេទ្រទឌិន-ហាស្ប៊ែន ហុចទៅឲ្យអ្នកដទៃកាន់ជំនួសវិញ ។ លុះប៉ូលទៅដល់ក្នុងបន្ទប់ហើយ គេឲ្យបុរសគមអង្គុយលើអាសនៈមួយ មានរបៀបរៀបចំយ៉ាងស្អាត ក្បែរកូនក្រមុំលោកអគ្គមហាសេនា , ចំណែកខាងបេទ្រទឌិន-ហាស្ប៊ែន ពួកអ្នកក្រុងបានរៀបចំដាក់ឲ្យនៅខាងស្ដាំបុរសគម ។

គេមើលទៅឃើញនាងក្រមុំគាត់តែងខ្លួន ដោយគ្រឿងអលង្ការយ៉ាងមានដម្លៃ, ប៉ុន្តែមើលទៅមុខមាត់មិនស្រស់សោះ ឃើញស្លក់ស្លេកស្លាំង ទំនងជាមានសេចក្ដីទុក្ខព្រួយយ៉ាងធ្ងន់, រឿងនេះបណ្ដាលមកពីអ្វីនោះ គេអាចទាយបានដោយងាយណាស់ ព្រោះនៅជិតនាងមើលទៅឃើញប្ដីតាក្រក់មុខក្រញូវខ្មៅក្រញេវ មិនសមជាគូស្នេហាសោះ ។ ពួកភរិយានៃនាម៉ឺនសព្វមុខមន្ត្រី - តូចធំទាំងអស់ព្រមទាំងស្រី ៗ ក្នុងកំពង់ទឹងស្រី ៗ ក្នុងក្រុងអង្គុយអមសងខាងតាមថ្នាក់តាមជាន់ខ្ពស់ទាប ដោយលំដាប់ហូរហែហើយ សុទ្ធតែតែងខ្លួនដោយគ្រឿងអាភរណៈយ៉ាងថ្លៃថ្លាទាំងអស់ គួរឲ្យពិតពិលរមិលមើលក្រៃពេក ; នាងទាំងអស់នោះកាន់ទៀនឆិះៗ ឆេះភ្លឺព្រោងព្រាតគ្រប់ៗដៃ ។

(មានត)

# ប្រវត្តិសាស្ត្រសង្ខេបប្រទេសចិន

## ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម ប្រែរៀបរៀង

អំពីប្រវត្តិសាស្ត្រសាកលសៀម

(តមក)

---

## អំពីព្រះរាជិនី វូ-ហៀវ

កាលព្រះបាទថៃ-សុង មហារាជមិនទាន់ទិវង្គតនោះ ព្រះបាទកៅ-សុង នៅជាមកុដរាជកុមារ មានចិត្តប្រតិព័ទ្ធនឹងស្ត្រីរូបស្រស់ល្អម្នាក់ ឈ្មោះនាងវូ-ហៀវ ដែលជាគូស្នំឯករបស់ព្រះរាជបិតា ។ លុះកាលព្រះបាទថៃ សុងមហារាជទិវង្គតទៅ តាមខត្តិយប្រពៃណី នាងស្នំគ្រប់ៗ គ្នា តោងកោរសក់បួសទៅនៅក្នុងទីព្រះបរមសពរបស់ព្រះមហាក្សត្រ ឯព្រះនាងវូ-ហៀវក៏ត្រូវកោរសក់បួសទៅនៅក្នុងទីនោះដែរ ប៉ុន្តែកាលដែលមកុដរាជកុមារ កៅ-សុង ឡើងគ្រងរាជសម្បត្តិជាព្រះរាជាធិរាជ ក្រុងចិនហើយ ទ្រង់មានព្រះបន្ទូលឲ្យហៅ ព្រះនាងវូ-ហៀវចេញពីទីផ្នូរព្រះបរមសពចូលមកនៅក្នុងព្រះរាជវាំងវិញ ។ គួរកត់ចាំជាគ្រាដំបូងដែលព្រះមហាក្សត្រចិនទ្រង់ធ្វើការល្មើសនឹងខត្តិយប្រពៃណី ហើយជាប្រផ្នូលអាក្រក់ក្នុងរាជវង្សថាំង ។ កាលនាងវូ-ហៀវចេញមកនៅក្នុងវាំងហើយ នាងក៏ទុកសក់ឲ្យហូតដល់សក់នាងដុះវែងល្មមប្រើការបាន គ្រាន់តែចូលមកនៅក្នុងវាំងបាន ២-៣ ថ្ងៃ នាងវូ-ហៀវក៏ទៅជាស្រីព្រះស្នំ

សំណប់គាប់ព្រះទ័យរបស់ព្រះបាទកៅ-សុន ហើយនៅវេលានោះព្រះបាទកៅ-សុនមានព្រះអគ្គមហេសីរួចទៅហើយផង ។ ការដែលនាងរូ-ហៀរបានទៅជាស្រីព្រះស្នំសំណប់ដូច្នេះហើយ ព្រះនាងនៅមិនទាន់អស់ចិត្តប៉ុន្តែបានឡើងកាន់ទីអគ្គមហេសីរបស់ព្រះបាទកៅ-សុន ទើបទំគិតរិះរកឧបាយឲ្យព្រះបាទកៅ-សុន បណ្ដេញព្រះអគ្គមហេសីចេញ ហើយខ្លួនឯងនឹងបានឡើងគង់លើបល្ល័ង្កជំនួសវិញ ។ នៅទីបំផុតព្រះនាងគិតឃើញឧបាយកលមួយយ៉ាង ដែលជាទុច្ចរិតកម្មយ៉ាងសាហាវក្រៃលែង គឺព្រះនាងរូ-ហៀរ មានព្រះឱរសមួយនឹងព្រះបាទកៅ-សុន ព្រះនាងឯងធ្វើឧបាយប្រហារកូនខ្ចីរបស់ខ្លួនឲ្យស្លាប់ទៅ ហើយក៏ក្រាបបង្គំទូលព្រះបាទកៅ-សុនថា ព្រះអគ្គមហេសីសម្លាប់កូនរបស់ព្រះនាង ដោយខ្លាចកូនព្រះនាងដណ្ដើមរាជសម្បត្តិ ។ ព្រះបាទកៅ-សុនក៏ជឿតាមដោយឥតពិចារណា ទើបឲ្យដកព្រះអគ្គមហេសីចេញពីតំណែង ហើយទ្រង់ឲ្យតាំងព្រះនាងរូ-ហៀរជាអគ្គមហេសីឡើង ប៉ុន្តែហាក់ដូចការទិញតំណែងអគ្គមហេសី ដោយជីវិតរបស់កូនកន្លោះ ។ អំណើះកាលតមក ព្រះបាទកៅ-សុនទ្រង់នៅមានព្រះទ័យអាឡោះអាល័យអគ្គមហេសីចាស់ ឬមួយទ្រង់ជ្រាបសេចក្ដីពិតអំពីរឿងសម្លាប់កជទោសនោះ តែមិនមានរឿងរ៉ាវពោលទុកឲ្យច្បាស់លាស់ ត្រាមួយទ្រង់លបចូលទៅរកមហេសីចាស់យ៉ាងស្ងាត់ៗ ។ ព្រះនាងរូ-ហៀរបានដឹងរឿងដូច្នោះ

ក៏មានព្រះរាជសារទៅបង្គាប់ ឲ្យកាត់ដៃកាត់ជើងរបស់មហេសីចេញ មុខ
គួរឲ្យអាណោចអាធ័មពន់ពេកណាស់ ដោយព្រះរាជាធិរាជក្រុងចិនមិន
ហ៊ានមានព្រះឱង្ការថាអ្វីមួយព្រះឱស្ឋឡើយ ។ តមកព្រះនាងវូ-ហៀវ
មានព្រះរាជឱរសនឹងព្រះបាទកៅ-សុង មួយអង្គ ទើបព្រះនាងឲ្យដក
ឱរសរបស់ព្រះអគ្គមហេសីចាស់ចេញពីតំណែងមកុដរាជកុមារ ហើយ
ព្រះនាងឲ្យតាំងព្រះរាជឱរសរបស់ព្រះនាងក្នុងតំណែងនេះឡើង ។ ក្រោ
យពីនេះ ព្រះនាងក្រាបទូលឲ្យព្រះបាទ កៅ-សុង ប្រហារជីវិតពួកមន្ត្រី
ចាស់ៗ ដែលតាំងខ្លួនជាសត្រូវនឹងព្រះនាងអស់ទៅជាចំនួនច្រើន ។

តាំងពីពុទ្ធសករាជ ១២០៣ មក កិច្ចការរបស់ស្រុកទេសធ្លាក់
ទៅនៅក្នុងព្រះហស្តព្រះនាងយ៉ាងដាច់ស្រេច តាមដោយពិតនោះ ព្រះ
នាងវូ-ហៀវមិនមែនជាស្ត្រីល្ងង់ខ្លៅទេ ។ អ្នកប្រាជ្ញពង្សាវតារជាតិ
ចិន បើទុកជាស្អប់ខ្ពើមព្រះនាងវូ-ហៀវនោះយ៉ាងណាក៏ដោយ ក៏នៅ
តែនិយាយអួតថា ព្រះនាងជាស្ត្រីឈ្លាសវៃប៉ិនប្រសប់គ្រប់គ្រងស្រុក
ទេសបានល្អជាងព្រះរាជស្វាមីទៅទៀត ព្រោះកិច្ចការដែលសំខាន់ៗ
របស់ស្រុកទេស បានប្រព្រឹត្តទៅដោយស្រួលរៀបរយទាំងអស់ អំណាច
ចិននៅក្រៅប្រទេសក៏គង់ទ្រង់នៅល្អដដែល ពួកទាហានចិនដែលចេញ
ទៅច្បាំងនឹងពួកមនុស្សព្រៃ ក៏នៅតែច្បាំងតស៊ូតបនឹងបន្ទាយ ទាំងការ
គ្រប់គ្រងខាងក្នុងស្រុកក៏មិនជាទន់ខ្សោយណាស់ណាទេ ប៉ុន្តែសេចក្តី

ក្តៅក្រហាយខ្លោចផ្សាទូលទៅនៅក្នុងរាជសំណាក់ ។ ពួកក្សត្រក្នុងរាជវង្សទាំង ត្រូវចាប់ខ្លួននាំទៅប្រហារជីវិតអស់ជាចំនួនច្រើនមិនមែនតិចទេឡើយ ពួកភរិយា និងបុត្ររបស់ក្សត្រអស់នោះ ត្រូវចាប់មកធ្វើជាទាសីរបស់ព្រះនាងរ៉ូ-ហៀវ ។ ទុកជាព្រះឧត្តមមហេសីធ្វើអំពើអាក្រក់ដ៏សាហាវដល់ម្ល៉េះហើយក៏ដោយ ព្រះបាទកៅ-សុង ក៏នៅតែមិនហ៊ានស្តីបន្ទោសថាអ្វីឡើយ ប៉ុន្តែទ្រង់ក្រៀមក្រំខ្លោចផ្សាក្នុងព្រះទ័យបន្តិចម្តង ៗ ឥតស្រាករហូតដល់ក្នុងពុទ្ធសករាជ ១២២៦ ព្រះរាជឱរសរបស់ព្រះអង្គដែលកើតនិងអគ្គមហេសីចាស់ ត្រូវព្រះនាងរ៉ូ-ហៀវដាក់ថ្នាំបំពុលស្លាប់ទៅ ។ ព្រះបាទកៅ-សុង បានទតឃើញព្រះរាជឱរសត្រូវថ្នាំបំពុលស្លាប់នៅចំពោះព្រះភក្ត្រដូច្នោះ ក៏នៅតែមិនហ៊ានមានព្រះរាជឱង្ការថាអ្វីមួយព្រះឱស្ឋឡើយ កាលព្រះរាជឱរសត្រូវគេបំពុលស្លាប់ទៅមិនយូរប៉ុន្មាន ព្រះបាទកៅ-សុងក៏ធ្លាក់តែក្រំព្រះទ័យខ្លាំងឡើងៗ ហើយទិវង្គតទៅក្នុងពុទ្ធសករាជ ១២២៦ នោះឯង ហើយទ្រង់ទិវង្គតទៅយ៉ាងមហាក្សត្រដែលខ្លាចប្រពន្ធបំផុតក្នុងលោក ដែលមិនគួរសោកស្តាយសោះឡើយ ។

ព្រះរាជាធិរាជកំឡោះ ទ្រង់ព្រះនាមថា ព្រះបាទចុង-សុង ជារាជ-ឱរសរបស់ព្រះបាទកៅ-សុង ដែលកើតនឹងព្រះនាងរ៉ូ-ហៀវ បានឡើងគ្រងរាជបល្ល័ង្កនៃមហាណាចក្រចិនតទៅ ។ ឯមហាក្សត្រព្រះអង្គនេះក៏

មានទំនងដូចមុនទៀត គឺមានព្រះមហេសីដែលមានចិត្តលោភលើសលន់ មានឧបាយកលក្រឡាប់ផ្កាប់ផ្កាត្រឡប់ត្រឡិន ទ្រង់ព្រះនាមថា ព្រះនាងវៃ-ជី ។ នេះក៏មានបំណងនឹងធ្វើតាមតម្រាប់ព្រះនាងវូ-ហៀវដែរ គឺចាប់ទាញយកអំណាចការត្រួតត្រាស្រុកទេសមកទុកក្នុងព្រះហស្តព្រះនាង ទើបជាហេតុកើតរឿងមិនចុះសម្រុងគ្នានឹងម្តាយក្មេក គឺព្រះនាងវូ-ហៀវ ។ ឃើញថាព្រះបាទចុង-សុងស្រឡាញ់ប្រពន្ធជាងម្តាយ ព្រះនាងក៏ដកព្រះបាទចុង-សុងចេញពីរាជសម្បត្តិ ហើយខ្លួនព្រះនាងឡើងជាព្រះរាជាធិរាជរបស់ក្រុងចិនយ៉ាងដាច់ស្រេច មិនមានបុគ្គលណាហ៊ានមកតក ពាំងរាជអំណាចតទៅទៀត ។ ឯពួកក្សត្រសាលោហិតរបស់រាជវង្សថាំងជាច្រើនអង្គ សឹងមានចិត្តទឹកអៀនខ្មាសនឹងការអាក់អន់ទោមនស្សជាបំផុត ដោយហេតុសាច់សាលោហិតរបស់លី-ចេមិន តោងរលំរលាយដោយស្នាដៃរបស់ស្រ្តី ដែលកាលពីដើមមកខ្លួននាងនោះមានសក្តិត្រឹមតែជាស្រ្តីព្រះស្នំម្នាក់ប៉ុណ្ណោះ ទើបនាំគ្នាបង្កការបះបោរឡើងតែបែរជាបរាជ័យ ហើយត្រូវគេកាត់ក្បាលនាំយកទៅថ្វាយ «សម្តេចព្រះរាជាធិរាជនៃក្រុងចិន» ទាំងអស់ ។

សម្តេចព្រះរាជាធិរាជនេះ ទ្រង់ធ្វើអកុសលកម្មដ៏សាហាវបំផុតក្នុងសម័យរបស់ព្រះអង្គ គឺការកាត់ក្បាលមនុស្សក៏បានកាត់ចេញៈហើយជាចំនួនច្រើន ដាក់ថ្នាំបំពុលសម្លាប់មនុស្សក៏បានធ្វើៈហើយ កាត់ដៃជើង

មនុស្សក៏ធ្លាប់ធ្វើហើយ ប្រពាត់កូនខ្ចីរបស់ខ្លួនសម្លាប់ក៏បានធ្វើហើយ បើដូច្នេះតើនៅមានអំពើអកុសលបែបណាទៀតខ្លះ ដែលព្រះនាងត្រូវធ្វើទៅទៀត? - ព្រះនាងត្រូវបុត្រនៃប្រទេសអេស៊ីប្ដ ធ្លាប់មានក្សត្រីឈ្មោះល្បីខាងធ្វើអំពើសាហាវៗ មកហើយ ក៏នៅតែមិនទាន់ដល់ពាក់កណ្ដាលព្រះនាងវូ-ហៅនេះឡើយ ។ ព្រះនាងវូ-ហៅ នៅមានលក្ខណៈមួយយ៉ាងទៀតនាំឱ្យអសោចក្សត្រឈ្មោះជាច្រើនណាស់ដែរ គឺព្រះនាងជាស្ត្រីមានចិត្តលោភកាមតណ្ហាក្រមានស្ត្រីដទៃប្រៀបផ្ទឹមបាន ត្រឹមតែគ្រហស្ថផងគ្នា មិនអាចផ្គាប់ព្រះទ័យព្រះនាងឱ្យបានឆ្អែតស្កប់ស្កល់នឹងកាមគុណទេ ទើបព្រះនាងឱ្យហៅភិក្ខុកំឡោះមួយរូបឱ្យចេញពីកុដិវត្តមកបម្រើព្រះនាង គ្រានោះ មានភិក្ខុកំឡោះរូបស្រស់មួយរូបព្រះនាងសព្វព្រះទ័យណាស់ ទ្រង់តាំងឱ្យធ្វើជាចៅអធិការក្នុងវត្តដែលធំបំផុតក្នុងក្រុងឡោ-យ៉ាំង ហើយទ្រង់អនុញ្ញាតឱ្យលោកនេះចេញចូលបានគ្រប់ពេលវេលាទាំងយប់ទាំងថ្ងៃ ។ ការប្រហារជីវិតមនុស្សក៏កាន់តែមានច្រើនឡើងរាល់ៗថ្ងៃ ហើយការកាត់ក្បាលមនុស្សនោះសោតទៀត គេក៏ធ្វើមែនៗ មិនមែនឆបោកបានទេ ព្រោះត្រូវនាំយកក្បាលមនុស្សដែលកាត់ហើយនោះ ទៅថ្វាយឱ្យទ្រង់ទតមើលព្រះនេត្រផង ។ ព្រះនាងវូ-ហៅទ្រង់តែងព្រះអង្គជាមហាក្សត្រ ហើយទ្រង់បំរុងនឹងតាំងព្រះរាជវង្សជាថ្មី ដោយការប្រគល់រាជសម្បត្តិ

ឲ្យពួកកូនក្មួយរបស់ព្រះនាង ។ ការធ្វើដូច្នោះជាការជ្រុលពេក ទើប
មានពួកមន្ត្រីដែលសុចរិតស្មោះត្រង់នឹងរាជវង្សថាំង ដែលត្រូវព្រះរាជា-
នុភាពព្រះនាងគេបង្កាប់ទាល់តែងើបក្បាលមិនរួចនោះ ក៏នាំគ្នាទទឹង
ទាស់យ៉ាងរឹងប៉ឹង សូម្បីពួកស្រុកចំណុះក៏នាំគ្នាយល់ទាស់ដែរ ។ គ្រា
នោះ មានក្សត្រតួកិមួយអង្គគង់នៅក្រៅដែនអាគេន មានកំឡាំងទាហាន
រឹងប៉ឹងគ្រាន់បើ ក្នុងវេលានោះហៅថា មេចូអ៊ី បានចេញប្រកាសថា បើ
អ្នកឯណាគិតបំផ្លាញរាជវង្សថាំងហើយ មេចូអ៊ីនឹងលើកទ័ពចូលលុក
ស្រុកមួយរំពេច ព្រះនាងវូ-ហៅ យល់ថា នឹងកើតចលាចលរឹតជា
ខ្លាំងទើបគិតគួរចងស្ពានមេត្រីនឹងមេចូអ៊ី ទើបចាត់រាជបម្រើឲ្យចូលទៅសុំ
ដណ្ដឹងកូនក្រមុំរបស់មេចូអ៊ី យកមកផ្សំផ្គុំឲ្យក្មួយព្រះនាង ដែលព្រះនាង
បម្រុងនឹងប្រគល់ឲ្យគ្រងរាជសម្បត្តិជាលំដាប់តទៅ តែមេចូអ៊ីមិនល្ងង់
ដល់ទៅទទួលយកក្មួយរបស់ព្រះនាង ទើបឆ្លើយតបទៅវិញថា ក្រៅ
អំពីសាច់សាលោហិតរបស់ ថៃ-ស៊ុងហើយ មិនមានបុរសដទៃមានសក្តិ
ស្មើគ្នានឹងកូនក្រមុំរបស់ខ្លួនឡើយ ។ កាលព្រះនាងវូ-ហៅ បានទទួល
ពាក្យតបជាសេចក្ដីមើលងាយប្រមាថដល់ព្រះបរមតេជានុភាពដូច្នោះ ក៏
ទ្រង់ក្រេវក្រោធលើសលុះគណនាហើយទ្រង់ចេញប្រកាសថា បើអ្នក
ឯណាមួយអាចកាត់ក្បាលមេចូអ៊ីយកមកថ្វាយបាន នឹងទ្រង់ប្រទាន
ទ្រព្យសម្បត្តិឲ្យទៅជាមហាសេដ្ឋី ។ ឯមេចូអ៊ី កាលបានជ្រាបដំណឹង

ដូច្នោះហើយ ក៏លើកទ័ពចូលទៅលុកលុយដែនចិន បានបំផ្លាញជីវិតទាហានចិនជាង ៩ ម៉ឺននាក់ ។

កាលមេចូអ៊ូស៊ាំដែនវិទ្ធិឲ្យឃើញស្ថានដូច្នោះ ព្រះនាងវូ-ហៀវចាប់ដឹងខ្លួនឡើងខ្លះ ទើបព្រមទទួលធ្វើស្ពានមេត្រីនឹងមេចូអ៊ូជាថ្មី ហើយយកកូនរបស់ខ្លួនដែលដកចេញពីរាជសម្បត្តិ យកខ្លួនទៅឃុំទុកនោះ ត្រឡប់ឲ្យឡើងសោយរាជ្យឡើងវិញ តែកិច្ចការរបស់ស្រុកទេសគង់នៅក្នុងកណ្ដាប់ដៃព្រះនាងទាំងអស់ ដល់មកសម័យនេះជន្មាយុរបស់ព្រះនាងកាន់តែជរាភាពណាស់ហើយ ទើបបានប្រគល់កិច្ចការសំខាន់ៗ ទុកនៅដៃរបស់មន្ត្រីប្រុសប្រាណ ២ នាក់ជាសែស ចាន ដែលគាល់បម្រើជិតព្រះបាទយុគលរបស់ព្រះនាងទាំង ២ នាក់ជានិច្ច ទាំងយប់ទាំងថ្ងៃ ។ នាងទាំង ២ នាក់បងប្អូនមានអំណាចធំបំផុត បើនឹងសម្លាប់ព្រះបាទចុង-ស៊ុង ហើយតាំងខ្លួនឯងឡើងគ្រងរាជ្យក្នុងពេលណា ក៏សឹងបានដូចបំណង ។ នៅគ្រានោះ ពួកក្សត្រិយ៍ក្នុងរាជវង្សថាំងទាំងអស់ ទ្រាំតទៅទៀតពុំបាន ដល់មកក្នុងឆ្នាំមួយ ក្នុងពុទ្ធសករាជ ១២៤៨ ពួកក្សត្រិយ៍អស់នោះ ក៏នាំគ្នារួបរួមកម្លាំងទាហានលើកចូលទៅក្នុងព្រះរាជវាំង បង្គាប់ឲ្យព្រះបាទចុង-ស៊ុងប្រាប់ឲ្យដាក់ដាច់អំណាចព្រះនាងវូ-ហៀវនៅត្រង់ណា ព្រះបាទចុង-ស៊ុងត្រូវតែបង្អួលប្រាប់តាមត្រង់ ហើយពួកក្សត្រិយ៍ទាំងនោះ ក៏នាំទាហានចូលទៅកាន់តំណាក់ព្រះនាង

ឡូ-ហៀវ ។ ខណៈនោះព្រះនាងតើនឡើងភិតភ័យស្រឡាំងកាំងព្រម ទាំងនាងពីនាក់បងប្អូន ដែលនៅនឹងព្រះបាទយុគលទាំងសងខាង ពួកទាហានចូលដល់ក៏យកដាវដាក់ផ្តាច់ទឹងក បង្គាប់ឲ្យចុះហត្ថលេខាលាចេញពីរាជសម្បត្តិ ឯនាងពីនាក់បងប្អូនក៏ត្រូវពួកទាហានចាប់អូសយកទៅសម្លាប់នៅចំពោះមុខព្រះនាង តែខ្លួនព្រះនាងឡូ-ហៀវនោះ គ្មាននរណាហ៊ានធ្វើអន្តរាយអ្វីឡើយ ដោយហេតុអ្វីមិនប្រាកដ ។ តែអំពីនោះមកបាន ២-៣ ថ្ងៃ ព្រះនាងក៏ក្ស័យព្រះជន្មទៅដោយពេគក្រៀមក្រំក្នុងព្រះទ័យ មានចំនងដូចជាព្រះរាជស្វាមីរបស់ព្រះនាង ។

តាំងអំពីព្រះនាងឡូ-ហៀវ បានធ្វើជាស្រីព្រះស្នំសំណប់របស់ព្រះបាទកៅ-ស៊ុង ក៏ព្យាយាមរួបរួមយកអំណាចនៃមហាណាចក្រចិនមកទុកក្នុងដៃ ក៏ជាប់មានមនុស្សស្អប់ខ្ពើមទឹងបង្កាឃាតព្យាបាទ តែបើឡែកណាស់គ្មាននរណាហ៊ានធ្វើអ្វីឡើយ ទាល់តែព្រះនាងស្លាប់ទៅតាមសម្ពរទិនណាយុសង្ខាររបស់ព្រះនាង ពួកដែលស្អប់ដេរប្រទេចផ្តាសាឲ្យព្រះនាងហិនទោកាត់ក្បាលក្តូនគោនរតាំពេលស្លាប់របស់ព្រះនាងអស់វេលាយូរណាស់ ព្រោះព្រះនាងមានព្រះជន្មាយុដល់ ៨១ ឆ្នាំ ទុកពេលឲ្យព្រះនាងគសាងកម្មពារមកដល់ ៤៥ ឆ្នាំ ទើបព្រះនាងទិវង្គតទៅ ។

អ្នកតាក់ប្រវត្តិសាស្ត្រចិនបានឃើញហើយថា ស្រីមានអំណាចត្រឹមណា ព្រះបាទកៅ-ស៊ុងនៅក្រោមអំណាចស្រីត្រឹមណា យើងគង់

យល់ថា មិនមានព្រះមហាក្សត្រអង្គណា ខ្លាចប្រពន្ធទៀតក្រៃលែងជាងព្រះបាទកៅ-សុងទៅទៀតទេ ឬមួយមិនមានព្រះរាជិនីអង្គណា ប្រព្រឹត្តអំពើអាក្រក់លាមកក្រៃលែងជាងព្រះនាងរូ-ហៅទៀតទេ បើគិតឃើញត្រឹមប៉ុណ្ណោះមិនទាន់ពេញជាត្រូវទេ ព្រោះស្រុកចិន នៅមានព្រះរាជពង្សរបស់មហាណាចក្រចិន ដែលខ្លាចប្រពន្ធរបស់ខ្លួនជាងព្រះបាទកៅ-សុងនោះនៅមានទៀត គឺព្រះបាទបុង-សុង ដែលទទួលគ្រងរាជសម្បត្តិជាតំណតមក ហើយព្រះរាជិនី ដែលអាក្រក់ជាងព្រះនាងរូ-ហៅក៏នៅមានទៀត គឺព្រះនាងវៃ-ជី អគ្គមហេសីរបស់ព្រះបាទបុង-សុង ដូចមានសេចក្ដីសារសព្វជាលំដាប់តទៅ ។

## អំពីព្រះបាទបុង-សុងនឹងព្រះនាងវៃ-ជី

ព្រះបាទបុង-សុង កាលរួចខ្លួតអំពីអំណាចបង្ខំសាហាវរបស់ព្រះរាជមាតាហើយ ក៏ត្រូវធ្លាក់ទៅក្រោមអំណាចព្រះនាងវៃ-ជី ជាអគ្គមហេសីទៀត ។ នៅសម័យដែលទ្រង់ត្រូវព្រះរាជមាតាដកចេញចាករាជសម្បត្តិទៅគង់នៅក្នុងគុកនោះ ព្រះនាងវៃ-ជីក៏តាមស្ដេចទៅរួមទុក្ខលំបាកជាមួយផង ហើយតែងប្រលោមលួងលោមព្រះទ័យព្រះបាទបុង-សុង រាល់តែទ្រង់យល់ថាព្រះនាងវៃ-ជីជាភរិយាល្អពិតៗ ហើយទ្រង់សព្វព្រះទ័យជាច្រើន ។ ប៉ុន្តែគំនិតស្រឡាញ់ក៏ក្លាយទៅជាខ្លាច លុះព្រះរាជមាតាទិវង្គតទៅហើយ ព្រះបាទបុង-សុង-

ក៏ប្រគល់អំណាចផែនដីឲ្យព្រះអគ្គមហេសី ពួកអាមាត្យមន្ត្រីនាំគ្នាក្រាបទូលឲ្យទ្រង់យល់ថា ការធ្វើដូច្នោះ មានតែវិនាសអន្តរាយ ទុកជាពួកអាមាត្យរាជបណ្ឌិត ក្រាបទូលអាងដល់សុភាសិតសាស្ត្រា ខុង-ជឺយ៉ាងណាៗ ក៏ដោយ ព្រះបាទចុង-សុងទ្រង់មិនយកព្រះកាណ៌ស្ដាប់ឡើយ ។ ការដែលពោលថា ព្រះបាទចុង-សុងខ្លាចប្រពន្ធជាងព្រះបាទកៅ-សុងទៅទៀតនោះ មិនមែនក្លែងពោលឲ្យលើសឡើយ ព្រោះអគ្គមហេសីត្រូវការ ព្រះរាជាធិការផង តែយល់ព្រមតាមទាំងអស់ ដូចជាព្រះអគ្គមហេសីត្រូវការមានប្រុសសហាយ ព្រះបាទចុង-សុង ក៏ទ្រង់យល់ព្រម ។ ព្រះនាងវ៉ៃ-ជី មីងមន្ត្រីកំលោះរូបស្រស់ម្នាក់ឈ្មោះរូសានសេ បានទៅមករកគ្នាយ៉ាងពេញមុខពេញមាត់ ទាល់តែកើតរឿងអពមង្គលឡើងក្នុងព្រះរាជសំណាក់ ព្រះបាទចុង-សុង ក៏មិនទ្រង់អើពើដល់មួយព្រះគុម្ព មានមន្ត្រីម្នាក់ចូលមកក្រាបបង្គំទូលឲ្យទ្រង់ចាត់ការលុបលាងរឿងអប្រិយនោះចេញ បែរជាមានព្រះរាជបញ្ជាឲ្យកាត់ក្បាលអ្នកដែលមកក្រាបទូលនោះថែមទៀត ។ បណ្ដាពួកអាមាត្យមន្ត្រីដែលត្រូវប្រហារជីវិតដោយរឿងនេះ មានអ្នកខ្លះធ្លាប់បានជួយទំនុកបំរុងឲ្យព្រះបាទចុង-សុងបានឡើងគ្រងរាជ្យក្រុងចិនក៏មាន ។

ឯព្រះនាងវ៉ៃ-ជីគិតតែខាងសប្បាយរីករាយខាងកាមគុណ យកប្រាក់រាជការបោះចោលខ្ជះខ្ជាយឥតស្តាយដូចដុំក្រួស កិច្ចការស្រុកទេសមិនរវល់ បណ្ដោយឲ្យកើតចលាចលសៅហ្មង ។ (មានត)

# រឿងស៊ុន-យ៉ាត់-សេន

អ្នកនយោបាយឯកជាតិចិន កាលជាប់ឃុំនៅក្រុងឡុងដ្រ៍

## លោក រ៉ាយ-ប៊ុក ប្រែពីភាសាបារាំង

(តមក)

---

លោកនោះនិយាយនឹងខ្ញុំវិញថា » អ្នកឈ្មោះស៊ុន-វេន (Sun-Win) យើងបានទទួលទូរលេខលោកឧបទូតចិន ប្រចាំប្រទេសអាមេរិក ឲ្យដំណឹងមកខ្ញុំថា "អ្នកឯងបានឡើងកប៉ាល់ឈ្មោះម៉ាស៊ីស្ទិក (Majistie) ឆ្លងមកដល់ទីក្រុងនេះហើយ មានបង្គាប់ឲ្យខ្ញុំរកចាប់ខ្លួនឲ្យបាន" ។

ខ្ញុំក៏តបទៅវិញថា "តើលោកចង់និយាយយ៉ាងណា?" —

កាលពីមុន លោកបានជូនពាក្យទៅតុងលីយ៉ាមេន (Tong-Li-Yamen) នៅក្រុងប៉េកាំង ដើម្បីនឹងសុំកែប្រែបញ្ជប់ប្រពៃណីរបស់ប្រទេសជាតិ ហើយបង្គំឲ្យបញ្ជូនពាក្យទៅសម្តេចព្រះមហាចក្រពត្តិម៉ង់គូលី ប៉ុន្តែហាក់ជាពាក្យនោះ មានសេចក្តីពុះពីសាណាស់ បានជាពួកតុងលីយ៉ា-មេន ត្រូវចាប់ខ្លួនអ្នក ។ ហេតុនេះអ្នកឯងត្រូវជាប់ឃុំខ្លួននៅទីនេះ ទម្រាំតែព្រះមហាចក្រពត្តិ មានព្រះរាជឱង្ការត្រាស់បង្គាប់ឲ្យសម្រេចពីរឿងអ្នកយ៉ាងណា ?

តើខ្ញុំឲ្យដំណឹងទៅមិត្តភក្តិខ្ញុំ ។ «មិនបានទេ» តែអ្នកឯងអាចសរសេរទៅភោជនីយដ្ឋានដែលអ្នកស្នាក់ ឲ្យគេយកអីវ៉ាន់មកឲ្យអ្នកបាន» ។

គេបានឲ្យប៉ាកកា ទឹកខ្មៅនិងក្រដាសមកខ្ញុំ ។ ក៏សុំសរសេរសំបុត្រទៅដល់លោកគ្រូពេទ្យ "ម៉ងសុង" ជូនដំណឹងពីការដែលគេឃុំខ្លួនខ្ញុំទុកក្នុងឋានអគ្គបជ្ជុតថិន ហើយ សូមឲ្យលោកជម្រាបដល់លោកតន់ទ្វី ឲ្យគេយកអីវ៉ាន់មកឲ្យខ្ញុំផង ៖ ឯលោកចាស់នេះតាមតែប្រចន្ទិប ទើបខ្ញុំស្គាល់ឈ្មោះ "សេរ៍ហាលីដេ (Sir Halliday) ។ នេះពន្យល់ខ្ញុំថា មិនត្រូវដាក់ថាជាមនុស្សជាប់ទោសទេ ត្រូវផ្លាស់ពាក្យនេះចេញទើបខ្ញុំសរសេរយ៉ាងនេះថា ខ្ញុំនៅក្នុងឋានបជ្ជុតថិន សុំឲ្យលោកឲ្យដំណឹងទៅលោកតន់ទ្វីផង ឲ្យលោកផ្ញើអីវ៉ាន់មកឲ្យខ្ញុំ" ។ រួចលោកនេះនិយាយឡើងទៀតថា ខ្លួនលោកមិនចង់ឲ្យខ្ញុំសរសេរទៅមិត្តភក្តិខ្ញុំ គ្រាន់តែឲ្យខ្ញុំប្រាប់គោដនិយដ្ឋាន ដែលខ្ញុំស្គាល់អស្រ័យបានហើយ ។ ខ្ញុំក៏បានតបទៅវិញថា ខ្ញុំមិនបានទៅស្គាល់កន្លែងគោដនិយដ្ឋានទេ មានតែលោកតន់ទ្វី, ទើបបានប្រាប់ទីកន្លែងដែលខ្ញុំនៅ » ។

ក្នុងពេលនោះ មិនបាច់ឿនឆ្ងល់ទេ លោកដែលសួរខ្ញុំនេះ ចង់ដើរនយោបាយយ៉ាងល្អិតសុខុម ដើម្បីនឹងដកហូតវត្ថុផ្សេង ៗ មានក្រដាសនឹងលិខិតសំបុត្រស្នាម ដើម្បីចង់ដឹងមិត្តភក្តិខ្ញុំដែលជាជាតិចិន ។

លុះខ្ញុំសរសេររួចហើយ ក៏ជូនលិខិតនោះទៅលោក ។ លោកបានមើលសំបុត្រនោះសព្វគ្រប់ហើយ ក៏ប្រគល់មកឲ្យខ្ញុំវិញថា "នេះល្អហើយ" ខ្ញុំក៏បញ្ចូលក្នុងស្រោម រួចជូនទៅលោកនោះវិញទៀត (សេរ៍.

ហល្លីដេ) ម៉ាកាទី (SirHalliday Macartney) ដោយខ្ញុំនឹកស្មានថា សំបុត្រខ្ញុំមុខជាបានទៅដល់លោកគ្រូម៉ង់សុនមិនខាន ។

រួចលោកសៀរហល្លីដេ ក៏ដើរចេញពីបន្ទប់នោះទៅ បិទទ្វារចាក់សោបន្ទប់ ខ្ញុំក៏ជាប់ឃុំនៅទីនោះ ។

នៅខាងក្រៅ មានអ្នកយាមពីរនាក់ ក្នុងពួកនេះមានជាតិអឺរ៉ុបម្នាក់ផង ។ ជួនកាលមានទាហានចិនមកចាំយាមល្បាតថែមទៀតក៏មាន ក្នុង២៤ម៉ោងដំបូង មានទាហានចិនយាមដើរចេញចូល ហើយនិយាយមកកាន់ខ្ញុំជាភាសារបស់ខ្លួន ពួកនេះឥតបានឲ្យពិតមានអ្វីមកខ្ញុំទេ ហើយខ្ញុំគ្រាន់តែសួរឈ្មោះលោកដែលចាស់ដែលបាននាំខ្ញុំយកមកឃុំទុកនៅទីនេះ ។

ពួកនោះឆ្លើយមកកាន់ខ្ញុំវិញថា គឺលោកសៀរហល្លីដេម៉ាកាទី «ម៉ាកា-ឈេន» ដែលគេធ្លាប់ហៅនៅទីនេះថា ព្រះបាទម្ចាស់ «ម៉ា» ។

អស់ពេលជាច្រើនម៉ោង តមកដែលខ្ញុំជាប់ឃុំមានទាហានយាមម្នាក់ចូលមកក្នុងបន្ទប់ខ្ញុំហើយ ពោលថា លោកសៀរហល្លីដេម៉ាកាទី បង្គាប់ឲ្យខ្ញុំត្រួតត្រាហោប៉ៅអាវអ្នក ។ រួចរើកកាយយកកូនសោ ឡៅដៃនឹងកាំបិតបត់ខ្ញុំ ព្រមទាំងប្រមូលយកក្រដាសសំបុត្រស្នាម ដែលកត់ត្រាពិតមានដែលគេបានដោយកម្រទៅ តែឥតបានឃើញហោប៉ៅខាងក្នុងអាវ ដែលមានធនប័ត្រ (ក្រដាសប្រាក់) ពីរបីសន្លឹកនោះឡើយ ។ គេបានសួរខ្ញុំថា លោកត្រូវការបរិភោគអាហារអ្វី? ខ្ញុំឆ្លើយថា ត្រូវការទឹក-

ដោះគោ ។ ក៏គេយកទឹកដោះគោមកឲ្យខ្ញុំ ។

មានអ្នកបំរើជាតិអង់គ្លេសពីរនាក់មកអុជភ្លើងបោសសំអាតកម្រាលឥដ្ឋ ។ ខ្ញុំសុំឲ្យបំរើម្នាក់ដែលបានចូលទៅក្នុងបន្ទប់ខ្ញុំមុនដំបូងឲ្យយកលិខិតមួយ ដែលខ្ញុំបានសរសេរទៅជូនលោកគង់ទី ។ ដល់បំរើម្នាក់ទៀតចូលមកទៀតខ្ញុំក៏សួរពីដំណើរដែលខ្ញុំចង់ផ្ញើសំបុត្រ ដូចបំរើមុននេះដែរ ។ ដល់ក្រោយមក ទើបខ្ញុំបានដំណឹងពីសំបុត្រនោះ តែអ្នកទាំងពីរបានប្រាប់ខ្ញុំថា បានផ្ញើទៅដល់អ្នកដែលត្រូវទទួលហើយ ។ ដល់ល្ងាចថ្ងៃអាទិត្យ មានកុមារអង់គ្លេសម្នាក់ចូលមករៀបចំគ្រែដេកខ្ញុំ ។ ឥតបានដេញដោលសួររឿងអ្វីឡើយ ខ្ញុំបានដេកទាំងសំលៀកបំពាក់ តែឥតបិទភ្នែកជិតឡើយ ។

ថ្ងៃក្រោយមកទៀត គឺថ្ងៃចន្ទ ១២ អុកតូប្រ៍ មានពួកបំរើជាតិអង់គ្លេសពីរនាក់ បានត្រឡប់ចូលមកដុះលានបន្ទប់ខ្ញុំ បានយកឡូស៍, ទឹក, និងម្ហូបអាហារមកឲ្យខ្ញុំ ។ មានបំរើម្នាក់ប្រាប់ខ្ញុំថា បានយកសំបុត្រ ដែលខ្ញុំបានប្រគល់ឲ្យវាជូនដល់ទីកន្លែង ម្នាក់ទៀតឈ្មោះកូល «Cole» តបមកខ្ញុំវិញថា លិខិតប្រហែលជាដល់ទីកន្លែងមិនខាន ។ ថ្ងៃអង្គារ ១៣ ខ្ញុំបានសួរបំរើដែលក្មេងជំទង់ (មិនមែនឈ្មោះ Cole) ថា អ្នកឯងបានឃើញលោកគង់ទី ហើយបានប្រគល់ឲ្យមែនឬទេ ? — វាតបមកវិញថា បានឃើញពិតប្រាកដ — ដោយខ្ញុំមានព្រួយបារម្ភក្នុងចិត្តជាច្រើន ទើបវាស្បថ

នឹងខ្ញុំថា ក៏បានឃើញលោកកន់ទូ ទទួលសំបុត្រនោះហើយលោកពោលពាក្យថា « ល្អហើយ » ។ ចួនជាពេលនោះគ្មានក្រដាសសរសេរ ទើបខ្ញុំសរសេរនឹងក្រដាសកូនកន្សែងដោយខ្មៅដៃ ហើយប្រាប់ឲ្យគេយកទៅឲ្យមិត្តភក្តិខ្ញុំទៀត ខ្ញុំបានប្រគល់ប្រាក់ជារង្វាន់ឲ្យគេកន្លះស៊ូវើរ៉ាំង (Demie-Souverain) = 10 Shilling: 12,60) ទៅគេដោយនឹកសង្ឃឹមថា គេមុខជាយកចិត្តទុកដាក់ក្នុងកិច្ចការរបស់ខ្ញុំ តែខ្ញុំមិនទាន់ទុកចិត្តពិតប្រាកដទេ.-រួចតមកទើបខ្ញុំបានដឹងថា គេយកវៀនក៏របស់ខ្ញុំទៅផ្ទាបទៅហ្វាយកាសគ្រប់ៗ

ថ្ងៃទី ៤ ក្រោយដែលខ្ញុំជាប់ឃុំនោះ មានឈ្មោះតាំង (Tang) ម្នាក់បានមកជួបនឹងខ្ញុំ ហើយខ្ញុំក៏ស្គាល់ជាក់ថា ឈ្មោះនេះឯងដែលបានចាប់ខ្ញុំមក ឈ្មោះនេះដាក់គួបគន្ធុយហើយពោលទៀតថា: "ឆាលដែលខ្ញុំបានឃើញអ្នកពីថ្ងៃមុនហើយបាននាំអ្នកមកដល់ទីនេះ ខ្ញុំគ្រាន់តែបំពេញកិច្ចរបស់ខ្ញុំប៉ុណ្ណោះ ឥឡូវខ្ញុំសុំបួលមកចរចាដោយមេត្រី, ប្រសិនបើអ្នកឯងទទួលសារភាពថា អ្នកឯងឈ្មោះ "ស៊ុន-វេន" មែន អ្នកឯងពេញជាគិតក្បត់, ម្ដេចក៏អ្នកឯងនៅតែប្រកែក ព្រោះការពិត គេបានឃើញអស់ហើយ ។

ឈ្មោះនេះក៏ពោលបញ្ជោរលោមចំអកផងថា អ្នកឯងមានកិត្តិសព្ទល្បីល្បាញនៅប្រទេសចិន, ហេតុការណ៍របស់អ្នក ព្រះមហាចក្រពត្តិនឹងពួកមន្ត្រី "ត្សុង-លី-យ៉ាមេន Tsong-Li-Yamen" បានជ្រាបអស់

ហើយ បើអ្នកមុខជានឹងស្លាប់ យើងត្រូវចាកចេញពីលោកនេះទៅ គួរទុកឈ្មោះឲ្យគង់វង្សកូនចៅតមតទៅ ពីព្រោះអ្នកឯងយកទៅទីនេះបាន សេចក្តីថា អ្នកឯងត្រូវរស់ ឬ ស្លាប់ អ្នកឯងដឹង ឬទេ?

ខ្ញុំក៏ស្រែកឡើងថា "ដូចម្តេច" យើងនៅប្រទេសអង់គ្លេសទេ តើ មិនមែនប្រទេសចិនទេ អ្នកឯងចង់យកខ្ញុំទៅធ្វើអ្វី បើអ្នកឯងចង់និរទេសពីទីនេះ ត្រូវអ្នកឯងឲ្យដំណឹងទៅរដ្ឋាភិបាលអង់គ្លេសជាមុនសិន អំពីរឿងខ្ញុំជាប់ឃុំ ។ ខ្ញុំមិនជឿថា រដ្ឋាភិបាលអង់គ្លេសបោះបង់ខ្ញុំចោលទេ ។

យើងមិនបាននិរទេសអ្នកឯងតាមផ្លូវច្បាប់ទេ កិច្ចការទាំងអម្បាល-ម៉ានគេបានចាត់ចែងទុកជាស្រេច នាវាគេបាននិយាយព្រមព្រៀងគ្នាជាមុនស្រេច អ្នកឯងត្រូវគេចងស្លាបសេកកន្ទ្រង់បុកមាត់ នាំយកអ្នកឯងចេញទៅស្ងាត់ឥតគង្វល់រវល់អ្វីទេ រួចឲ្យចុះនាវាមានពាហានយាមរក្សា រហូតទៅដល់ហុងកុង ហើយឲ្យអ្នកឯងចុះកប៉ាល់តូចមួយនាំអ្នកទៅស្រុកកន្តាំង ដើម្បីសំរេចកាត់ទោសប្រហារជីវិតចង់ ។

ខ្ញុំបានឆ្លើយតបវិញថា គំនិតអស់នេះមិនទាន់ច្បាស់លាស់ប្រាកដជាឥតហេតុសោះទេ ក្នុងខណៈដែលខ្ញុំជិះនាវាធ្វើដំណើរទៅ ប្រហែលជាខ្ញុំមានកិច្ចសំណាង បានជួបនិយាយគ្នានឹងពួកជនជាតិអង់គ្លេសមិនខានទេ ។

ចិនតាំងឆ្លើយថា "មិនបានទេ" ។ អ្នកឯងត្រូវគេឃុំខ្លួនទុកលើនាវាយ៉ាងម៉ឺងម៉ាត់ ជាងអ្នកឯងនៅទីនេះទៅទៀត ព្រោះហេតុដូច្នេះ បានជាអ្នកឯងមិនឃាយនឹងគេរួចឡើយ ។

ខ្ញុំនិយាយតបទៅវិញថា ពួកសេនាទាហានដែលនៅលើនាវានោះ ដោយស្មានទៅប្រហែលជាមិនមានចិត្តស្រដៀងដូចបច្ចាមិត្តខ្ញុំទេ ហើយប្រហែលជាមានលោកខ្លះ មានចិត្តអាណិតអាសូរខ្ញុំជួយសង្គ្រោះខ្ញុំឲ្យផុតរបូតពីវិនាសកម្មមិនខាន ។

ចិនតាំងឆ្លើយឡើងថា នៅលើនាវានោះសុទ្ធតែជាមិត្តភក្តិលោកឡេអៀវហេល្លីដេម៉ារតេនី ។ ពួកនេះមុខជាធ្វើតាមបង្គាប់ចៅហ្វាយនាយរបស់ខ្លួន ។ ហើយចិនតាំងនិយាយទៅទៀតថា, ត្រូវឲ្យខ្ញុំចុះកប៉ាល់មួយដែលដើរតាមផ្លូវនាវិកសាស្ត្រគ្លែន (ligne de navigation Glen) តែខ្ញុំមិនទាន់បានធ្វើដំណើរចេញទៅនៅសប្តាហ៍ក្រោយនេះទេ (យើងឥឡូវថ្ងៃ ១៤ ឧតុប៍) ពីព្រោះលោករដ្ឋមន្ត្រីមិនបានជួលនាវាតាមកំណត់នោះ លោកចង់ដឹកនាំទំនិញទៅមុនសិន ហើយលោកគ្រាន់តែចេញថ្ងៃយានជំនិះពួកអ្នកដំណើរប៉ុណ្ណោះ ។

ដល់សប្តាហ៍ក្រោយ ដល់ដឹកទំនិញរួចហើយ ទើបអ្នកឯងត្រូវចុះកប៉ាល់ទៅ ។

ហើយខ្ញុំនិយាយទៀតថា គ្រាន់ការបែបនេះពិបាកនឹងធ្វើការឲ្យបានផលសម្រេច ។

ទើបចិនតាំងតបមកវិញថា បើយើងខ្លាចហេតុរាំងនេះ យើងនឹងសម្លាប់លោកនៅទីនេះក៏បាន ព្រោះទីនេះជាស្រុកចិន ហើយគ្មានអ្នកណាមួយអាចតក់ទឹងពួកមន្ត្រីហានអ្នកជួតបានទេ ។

ដើម្បីទីងធ្មមចិត្តខ្ញុំ ចិនតាំងបានលើកឧទាហរណ៍មកប្រៀបថា មានបុគ្គលស្នេហាជាតិ ១ គូរ ដែលបានរត់ចេញពីប្រទេសកូរ៉េ បំណងនឹងទៅប្រទេសជប៉ុន មានពួកញាតិក្នុងស្រុកជាមួយបានណែនាំបុគ្គលនោះ ឲ្យទៅខាងស្រុកជាមួយ បានណែនាំបុគ្គលនោះឲ្យទៅខាងស្រុកសៀងហៃ ហើយគេក៏បានចាប់យកទៅប្រហារជីវិតបង់ នៅជិតភូមិរបស់អង់គ្លេស រួចពួកចិនបានផ្ញើសពទៅប្រទេសកូរ៉េវិញ ដើម្បីឲ្យតុលាការសម្រេចទោស ហើយគេបានយករូបនោះទៅកាប់ចិញ្ច្រាំ រួចគេបានឲ្យផ្ញើនដល់អ្នកធ្វើការមុខក្រសួងជំនាប់ប្រទេសនោះ ។

ខ្ញុំយល់បានថា ពេលនោះ ចិនតាំងមានចិត្តសង្ស័យថាចង់ឲ្យរដ្ឋាភិបាលចិន ដំកើងយសសក្តិឡើង ដោយហេតុបានចាប់សម្លាប់ខ្ញុំ ។

ខ្ញុំក៏បានសួរចិនតាំងតទៅទៀតថា ម្តេចក៏អ្នកឯងមានចិត្តអាឃាតព្យាបាទខ្ញុំខ្លាំងម្ល៉េះ ?

ចិនតាំងតបថា ព្រះរាជទូតនៃព្រះមហាចក្រពត្តិត្រាស់បង្គាប់ថា

ត្រូវចាប់អ្នកស្លាប់ឬរស់ឲ្យខានតែបាន ។

ក្នុងបរិយោសាន ខ្ញុំបានពន្យល់ថា ហេតុរឿងរ៉ាវជាតិក្បូរនេះ ហើយ ដែលនាំឲ្យមានចម្បាំងជុំន ហើយការចាប់ខ្ញុំទៅប្រហារជីវិតបង់ទៅនោះ នាំឲ្យមានរឿងរ៉ាវលំបាកតទៅខាងមុខជាអនេកប្រការ ។

ខ្ញុំថា: រដ្ឋាភិបាលអង់គ្លេសអាចធ្វើទណ្ឌកម្មពួកមន្ត្រីនៅស្ថានអគ្គរាជ-ទូតចិននេះក៏បាន – ហើយអ្នកឯងជាពលរដ្ឋនៅក្នុងស្រុកជាមួយនឹងខ្ញុំ ៗ អាចប្រាប់ឲ្យបក្សពួកខ្ញុំនៅខែត្រកាន់តុង ធ្វើការសងសឹកអ្នកទីញាតិសាលោហិតរបស់អ្នកទៀតក៏បាន ។

ចិនតាំងក៏ប្រែសំដីពន្យល់ខ្ញុំថា ដែលខ្លួនកាន់ធ្វើ គឺធ្វើតែតាមបញ្ជាស្ថានអគ្គរាជទូតហើយដែលមកសួរចំពោះស្នារបស់អ្នក គឺដោយសេចក្ដីមេត្រីតែប៉ុណ្ណោះ ។

* *
*

## ការជជែកជាមួយនឹងទាហានយាមដើម្បីប្រើនយោបាយ ដោះខ្លួនឲ្យរួចរស់ជីវិត

ដល់ម៉ោង ១១ យប់ ចិនតាំងបានត្រឡប់មកកាន់បន្ទប់ខ្ញុំ ហើយបានសួររឿងរ៉ាវដូចមុននោះទៀត ខ្ញុំក៏បាននិយាយថា អ្នកឯងល្មមធ្វើជាកល្យាណមិត្តរបស់ខ្ញុំបានហើយ ចុះអ្នកអាចជួយសង្គ្រោះខ្ញុំបានឬទេ? ចិន

ក៏ឆ្លើយថា ហេតុដូច្នេះបានជាខ្ញុំមកជួបនឹងលោកនៅទីនេះទៀត ខ្ញុំគិតរកឧបាយដើម្បីឲ្យលោកចេញពីទីនេះឲ្យបានឆាប់ - ប៉ុន្តែការនេះត្រូវបង្អង់បន្តិចសិន គឺពេលនេះ ខ្ញុំបានឲ្យជាងសោធ្វើកូនសោពីរ ១ សម្រាប់បន្ទប់លោក ១ ទៀតសម្រាប់ទ្វារបូល ។

ចិនតាំងត្រូវតែប្រើឧបាយបែបនេះ ពីព្រោះបម្រើរបស់លោកវេជ្ជបណ្ឌិត ដែលលោកទុកចិត្តណាស់នោះមានកូនសោពីរដាក់ជាប់នឹងខ្លួនជានិច្ច ។

ដោយខ្ញុំអធិប្បាយពីកិច្ចការដែលខ្ញុំប្រឹងនឹងរត់ចេញពីទីនេះ គឺកាលខាងមុខ ។ ចិនតាំងឆ្លើយថា ពេលនេះ លោកគិតការនេះមិនសម្រេចទេ ប៉ុន្តែបើដល់ទៅថ្ងៃសុក្រខាងមុខនេះ ពេលម៉ោងពីរព្រឹក ប្រហែលជាបានការ មុនចិនតាំងនឹងចាកចេញពីខ្ញុំទៅ ចិនតាំងប្រាប់ខ្ញុំថា ត្រូវលោកប្រុងប្រៀបឲ្យស្រេចដល់ថ្ងៃសុក្រនោះលោកនឹងបានរួចខ្លួនមិនខាន — ដល់ចិនតាំងចេញផុតទៅ ខ្ញុំក៏បានសរសេរលិខិត ១ ទៅលោកគង់ធី ឲ្យបម្រើម្នាក់យកទៅជូន —

ស្អែកព្រឹកថ្ងៃព្រហស្បតិ៍ ១៥ ឧកតូប៍ ខ្ញុំបានប្រគល់លិខិតនោះឲ្យបម្រើម្នាក់នៅទីនោះ តែដល់ថ្ងៃរសៀលតាមពាក្យចិនតាំងថា ពួកបម្រើបានឲ្យលិខិតនោះដល់ពួកពជការមុខក្រសួង ហានអត្តពជខ្លួនទៅហើយ ។ ចិនតាំងថា ដោយកិច្ចការលោមកដែលលោកបានធ្វើតាំងអម្បាលម៉ាន លោកធ្វើឲ្យខូចការដែលខ្ញុំបានផ្ដើមធ្វើ ដើម្បីឲ្យ

លោកវត់ចេញពីទីនេះ ហើយសៀវហៅស្ទ័ដេម៉ារកាន បានបន្ទោសខ្ញុំជាទន្ទន់ ដោយខ្ញុំបានបំភ្លឺកិច្ចការឲ្យលោកដែលគេប្រឹងនឹងធ្វើចំពោះលោក ។ ដល់ចប់ការសន្ទនា ខ្ញុំក៏សួរទៅប៊ិនតាំងវិញទៀតថា ចុះខ្ញុំមានសង្ឃឹមថា នឹងបានរស់រួចជីវិតឬទេ ?

ប៊ិនតាំងតបមកវិញថា ក្នុងពេលនេះ លោកមានសង្ឃឹមច្រើន ប៉ុន្តែលោកត្រូវប្រតិបត្តិតាមខ្ញុំបង្គាប់គ្រប់ ៗ កុំឲ្យឃៀងឃ្លាតឡើយ ។

ប៊ិនតាំងប្រាប់ខ្ញុំឲ្យសរសេរពាក្យមួយទៅជូនលោករដ្ឋមន្ត្រីជាអគ្គរាជ-ទូត សូមឲ្យលោកប្រោសប្រណីទោសនោះ ។ ខ្ញុំក៏យល់ព្រមធ្វើតាម ហើយ ខ្ញុំក៏សូមបារីកាចក់ខ្មៅនិងក្រដាស ។ ប៊ិនតាំងបានបង្គាប់ទៅឈ្មោះគួលដែលជាបម្រើជាតិអង់គ្លេស ឲ្យយកប្រដាប់សរសេរមកឲ្យខ្ញុំសព្វគ្រប់ ៗ ខ្ញុំបានចារយកទឹកខ្មៅចិន ដោយខ្ញុំយល់ថា ទឹងសរសេរជាភាសាអង់គ្លេសទៅរដ្ឋមន្ត្រីខ្ញុំមិនសមគួរ ។ តែប៊ិនតាំងប្រាប់ខ្ញុំថា សរសេរជាភាសាអង់គ្លេសប្រសើរជាង ពីព្រោះលោករដ្ឋមន្ត្រីមានតែឈ្មោះទេនៅទីនេះ កិច្ចការសព្វសារពើស្រេចនៅលើលោកម៉ារកានទាំងអស់ ។ រួចខ្ញុំសួរទៅប៊ិនតាំងទៀតថា ត្រូវឲ្យខ្ញុំសរសេរដូចម្តេចខ្លះ ។ ប៊ិនតាំងថា :

« ត្រូវលោកបដិសេធថា លោកមិនបានចូលទៅសមាគម ជាមួយនឹងពួកក្រុមសម្ងាត់ នៅខែកត្តាំងទេ គឺខ្លួនលោកត្រូវពួកមន្ត្រីទាំងនោះ

តែងតែចងចាំ ហើយលោកបានចូលមកកែហាទកជនុតចិននៅក្នុង ឡុងដ៍នេះ ដើម្បីឲ្យគេកែសេចក្ដីយុត្តិធម៌ ក្នុងរឿងនេះ" ។

ខ្ញុំក៏បានសរសេរតាមពាក្យ ដែលចិនតាំងបានប្រាប់មក ពាក្យនោះ វែងរួចខ្ញុំដាក់ចូលក្នុងស្រោមដើរទៅជូនលោកសៀរហាល្វីដេម៉ារកាន់ទី ។ ខ្ញុំក៏ហុចសំបុត្រនោះទៅចិនតាំង ៗ ក៏យកចេញពីបន្ទប់ខ្ញុំទៅ លែងឃើញកាំរិបេត្រឡប់មកវិញឡើយ ។

ជាស់ខ្ញុំត្រិះរិះវែងឆ្ងាយទៅទើបឃើញថា ការដែលខ្ញុំធ្វើដូច្នោះ គាំសេចក្ដីល្អនិល្អិតពន់ពេក ៗ ដ្បិតខ្ញុំឲ្យការថា ខ្ញុំបានចូលមកដោយចិត្តឯង ដើម្បីតក់ពីរឿងរបស់ខ្លួន ។

ខ្ញុំបានគិតហើយរួចគេហើយថា ចិនតាំងឲ្យជំណាំខ្ញុំថា លិខិតតាំងគម្រាលមានរបស់ខ្ញុំរួចបំរើតាំងនោះ បានយកទៅឲ្យបញ្ចាមិត្តរបស់ខ្ញុំតាំងគស់ គតមានសំបុត្រណាមួយទៅដល់លោកពកន៍ឡឺជាគណ្ណាណមិត្តរបស់ខ្ញុំទេ ។

ខ្ញុំក៏ព្យាយាមបោះសំបុត្រទៅតាមបង្អួច ឲ្យធ្លាក់ចេញទៅក្រៅ ជូនជាសំណាងល្អ មានសំបុត្រសោតធ្លាក់ទៅលើដំបូលផ្ទះអ្នកជិតខាង ៗ ដោយខ្ញុំចង់ឲ្យសំបុត្ររបស់ខ្ញុំធ្លាក់ទៅទីឆ្ងាយ ៗ ខ្ញុំក៏ចង្កឹះលុយសេនរុំជាមួយក្រដាសបោះបេតែងតែបោលទៅដល់តែគស់ប្រាក់សេន ខ្ញុំក៏យកប្រាក់ស្ពឺងរុំក្រដាសបោលទៅដូចមុនទៀត តែសំណាងមិនល្អ មានសំបុត្រ ១

(មានត)

# សង្គហធម៌

## របស់ព្រះវិន័យធម្ម យូរ-ប៉ុណ្ណ

នៅវត្តឧណ្ណាលោម

ជាក្រុមជំនុំព្រះត្រៃបិដកក្នុងពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

វេលានេះ អាត្មាភាពនឹងសំដែងអំពីសង្គហធម៌ ដែលជាធម៌សម្រាប់សង្គ្រោះដល់គ្នានឹងគ្នា; សូមអស់លោកអ្នកទាំងឡាយចាំស្តាប់ដូចសំដែងតទៅនេះ:

កិច្ចឧបាយដែលសម្រាប់សង្គ្រោះឬស្រោចស្រង់គ្នានឹងគ្នាឲ្យបានមូលមិត្រហៅថា សង្គហៈ ។ សង្គហៈនេះបែកចេញជា ៤ យ៉ាងគឺ:

១ - ទាន: ការចែករំលែកឲ្យ

២ - បេយ្យវជ្ជ: ការពោលពាក្យពីរោះ គួរឲ្យចាប់ចិត្ត

៣ - អត្ថចរិយា ការប្រព្រឹត្តឲ្យជាប្រយោជន៍ដល់គ្នានឹងគ្នា

៤ - សមានត្តតា ភាពជាអ្នកតាំងខ្លួនឲ្យស្មោះស្មើចំពោះបុគ្គលជនគ្នា ។

សង្គហធម៌ទាំង ៤ យ៉ាងនេះ តែងប្រមូលជនទាំងឡាយឲ្យមូលមិត្រគ្នាក្នុងសកលលោក ។ បើសង្គហធម៌នេះមិនមានហើយ សាមគ្គីគឺការព្រមព្រៀងមូលមិត្រគ្នា ក៏នឹងធ្លុះធ្លាយបែកបាក់ទៅពុំខាន ។

ព្រះពុទ្ធជាម្ចាស់ទ្រង់សរសើរសង្គហធម៌នេះ ថាជាកិច្ចយ៉ាងប្រសើរបំផុតក្នុងលោក ។

ឯការសង្គ្រោះនេះ ជាចរណៈរបស់បុគ្គលអ្នកស្ថិតនៅក្នុងទីជាបុព្វការី ដូចជាមាតាបិតាមានការៈខាងសង្គ្រោះបុត្រធីតា; អាចារ្យមានការៈខាងសង្គ្រោះសិស្ស; ចៅហ្វាយនាយមានការៈខាងសង្គ្រោះទាសកម្មករ, ឥស្សរជនមានព្រះរាជាជាដើម មានការៈខាងសង្គ្រោះដល់ប្រជារាស្ត្រ ។

ជនដែលបានធ្វើសេចក្ដីសង្គ្រោះចំពោះរូបណាមួយហើយ ជននោះឈ្មោះថាជាបុព្វការី, ជនជាបុព្វការីនោះក៏គួរទទួលយកកិច្ចដែលគេត្រូវធ្វើមកវិញ ។ សូម្បីតែជនអ្នកខ្លួនមិនគិតប្រយោជន៍ផ្ទាល់ខ្លួន ហើយមានចិត្តមេត្តាសង្គ្រោះដល់ញាតិឯទៀត ។ ក៏គង់មានអ្នកដទៃគេរាប់អានជួយលើកដំកើងឲ្យទៅកាន់ទីជាធំបាន ។ ព្រោះហេតុនោះបានជាព្រះពុទ្ធជាម្ចាស់ ទ្រង់មានបំណងនឹងនាំសត្វឲ្យបានសម្រេចគុណសម្បត្តិ គឺការតាំងខ្លួនក្នុងធម៌ ទើបទ្រង់សំដែងនូវសង្គហឧបាយនេះទុកជាផ្លូវដំបូងដែលបានពោលមកខាងដើម រួមចូលដោយសង្ខេបជា ៤ គឺៈ ទានៈ, បេយ្យវជ្ជៈ, អត្ថចរិយា, សមានត្តតា ដូច្នេះ ។

ទី ១ ទានៈ ការឲ្យនោះ ចែកចេញជា ២ យ៉ាង គឺឲ្យសំដៅចំពោះរូបបុគ្គលម្នាក់ៗ ហៅថាអសាធារណទាន ១, ឲ្យជាសាធារណៈទូទៅមិនសំដៅចំពោះរូបបុគ្គលម្នាក់ៗ ហៅថា សាធារណទាន ១ ។ ដូច

ជាមាតាបិតាឲ្យអាហារ គ្រឿងប្រដាប់ស្លៀកពាក់ដល់បុត្រធីតាក្នុងវេលាដែលនៅកំឡោះក្រមុំ ឬឲ្យទ្រព្យសម្បត្តិធ្វើជាដើមទុន ឲ្យទិញផ្ទះសម្បែង ក្នុងកាលដែលបុត្រធីតាចំរើនវ័យហើយ; ចៅហ្វាយនាយឲ្យភោគសម្ប័ទដល់ទាសកម្មករ ញាតិមិត្រចែកចាយគ្រឿងប្រើប្រាស់និងភោជនាហារដល់គ្នានឹងគ្នា ៗ បុត្រធីតាដែលមានផ្ទះសម្បែងហើយបានជូនភោជនាហារ គ្រឿងស្លៀកពាក់ដល់មាតាបិតាដែលចាស់ជរា; ទាសកម្មករធ្វើការងារ ឬជូនរបស់ដល់ចៅហ្វាយនាយជាហេតុសំដែងសេចក្ដីចងមេត្រីទៅនឹងចៅហ្វាយនាយ; យ៉ាងនេះហៅថា អសាធារណទាន គឺបូជា ឬតបគុណចំពោះបុគ្គលម្នាក់ៗ ។

ឥស្សរជន ឬ អ្នកមានទ្រព្យសម្បត្តិ ជាអ្នកមានចិត្តផ្សាយមេត្តាអាណិតអាសូរប្រណីដល់មហាជន ហើយលះបង់សេចក្ដីកំណាញ់ បរិច្ចាគទ្រព្យផលគេឲ្យលើកថ្នល់ ជីកព្រែក ធ្វើស្ពាន ដើម្បីជាផ្លូវគមនាគមន៍ទៅមកបានស្រួល, សង់សាលា ដាំដើមឈើ ជីកស្រះដើម្បីជាទីសំណាក់អាស្រ័យដល់មនុស្សអាគន្តុកៈ តាំងបង្កើត ឬទំនុកបម្រុងធ្វើផ្ទះពេទ្យជាទីព្យាបាលរោគសព្វយ៉ាង, តាំងបង្កើត ឬទំនុកបម្រុងសាលាបង្រៀនជាទីឲ្យចំណេះវិជ្ជាដល់កុមារកុមារី ។ យ៉ាងនេះហៅថាឲ្យឬសង្គ្រោះជាសាធារណៈមិនចំពោះបុគ្គល ៗ ទានមានសភាពយ៉ាងនេះអាចឲ្យសេចក្ដីសុខដ៏ធំទូលាយ ជាងឲ្យចំពោះបុគ្គលម្នាក់ៗ ព្រោះ

ពន្រីកមេត្តាចិត្តផ្សាយទៅក្នុងលោកទាំងមូល ។ ពាទះការឡើងរួសង្គ្រោះ ដោយផ្សាយមេត្តាចិត្តយ៉ាងនេះ ហាត់ជាបារមី ១ ហៅថា ទានបារមី ។ ទានបារមីនេះព្រះពុទ្ធជាម្ចាស់ធ្លាប់បានបំពេញបានសន្សំមកច្រើនជាតិឥត គណនាឡើយ, លុះព្រះអង្គបានត្រាស់ហើយទ្រង់សំដែងនូវសង្គហទាន នេះ ថាជាកន្លែងថ្ងៃដំណើរនៃសេចក្តីសុខក្នុងលោកនេះ និងលោកខាង មុខ; នេះជាសង្គហទី ១ ។

ទី ២ បេយ្យវជ្ជៈ បើត្រាន់តែឲ្យចំណោះ បុរិន្តមិនបានពោល ពាក្យពិរោះគួរឲ្យពាប់ចិត្តផងទេ, វត្ថុដែលឲ្យនោះ បើទុកជាច្រើនយ៉ាង ណាក៏ដោយចុះ ក៏ប្រាកដជាក់ដូចជាតិច, បើពោលពាក្យពិរោះគួរឲ្យ ស្រណោះចាប់ចិត្ត, ក៏វត្ថុដែលឲ្យនោះ សូម្បីតិចតួចសោះ ក៏ប្រាកដ ហាក់ដូចជាច្រើន, ព្រោះធ្វើឲ្យកើតសេចក្តីស្រឡាញ់ពេញចិត្ត ធ្វើគុណ ដែលមានខ្លួនបងាៈឲ្យជាទីពេញអាណាត្រៃលែងឡើង ។ ព្រោះហេតុនោះបាន ជាព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ពាត់បេយ្យវជ្ជៈ ថាជាសង្គហទី ២ ។

បេយ្យវជ្ជៈ ប្រែថាពាក្យដែលពិរោះគួរពេញចិត្ត គួរចាប់ចិត្ត បែក ចេញជា ២ យ៉ាងគឺៈ បិយវាចា បានខាងវាចាពីរោះទន់ផ្អែម ធ្វើគុណ និយាយឲ្យជាទីស្រឡាញ់របស់អ្នកស្តាប់ ១, អត្ថសញ្ហិតា វាចា វាចាប្រកបដោយប្រយោជន៍ ១ ។

បិយវាចា អាចទឹកទាញចិត្តមនុស្សក្នុងលោកឲ្យស្រឡាញ់ចង់ រកគ្នាបាន, ដូចជាមាតាបិតា បីបាច់បុត្រធីតាដោយពាក្យទន់ផ្អែមដូចហៅថា កូន ថា នាង ដូច្នេះជាដើម ពាក្យនេះគួរឲ្យជាប់ចិត្តដល់បុត្រធីតាពន់ពេក ធ្វើឲ្យកើតសេចក្ដីស្រឡាញ់ ៗ បុត្រធីតាដែលចេះនិយាយពាក្យពីរោះគួរឲ្យជាប់ចិត្ត, មាតាបិតាក៏ស្រឡាញ់ពេញចិត្ត ៗ ជនជាផ្សេងៗដែលឈ្លាសក្នុងការបដិសន្ថារពោលពាក្យរាក់ទាក់ប្រសើរ រួសរាយដល់អ្នកគួរទៅគ្រប់ជាន់ គ្រប់ថ្នាក់, រមែងធ្វើខ្លួនឲ្យជាទីស្រឡាញ់ពេញចិត្តរបស់មនុស្សទាំងឡាយ ចេះនិយាយដឹកនាំអ្នកគួរឲ្យមានគំនិតធ្វើកិច្ចការដោយសេចក្ដីប្រឹងប្រែង ហើយឲ្យជាសុចរិតបានផង ៗ វាចាទន់ភ្លន់នេះឯង ធ្វើឲ្យជាមនុស្សនោះពីដើមកម្លាំងទាស់ទែងខ្វែងគំនិតគ្នា ដល់ទៅមើលមុខគ្នាមិនត្រង់ក៏ដោយ កាលបើបានឮសំដីពីរោះឲ្យយ៉ាងក៏អាចនឹងស្រាយកំហឹងនោះបាន ៗ ដូចពាក្យបុរាណលោកពោលថា "សំដីជាឯក លេខជាទោ" សំដីនេះលើកទុកជាទីមួយ ចំណេះវិជ្ជាទុកជាទីពីរ ៗ អ្នកដែលមានចំណេះយ៉ាងណាក៏ដោយចុះ, ប៉ុន្តែបើពោលវាចាមិនជាទីគាប់ចិត្តជាវាចាគំរោះគំរើយមិនពេញចិត្តអ្នកស្ដាប់ អ្នកមានចំណេះនោះ ក៏នៅជាឥតមានគេរាប់អានទៅវិញ ៗ ជនអ្នកខ្សត់ខ្សោយចំណេះវិជ្ជាសោះទេ, ប៉ុន្តែបើមានវាចាពីរោះ ចេះទន់លំទោនសុភាពរាបសាគួរឲ្យពេញចិត្ត, នឹងមានអ្នកដទៃគេចាប់ចិត្តជួយសង្គ្រោះ គេបូជា ឬឲ្យគុ

នេះនោះពុំមាន ។ យ៉ាងនេះក៏ជាឃោសារតែពាក្យពីរោះ ។ ប៉ុន្តែមនុស្ស ម្នាក់ៗ មិនត្រូវធ្វើខ្លួនឲ្យឥតចំណេះវិជ្ជាទេ, ត្រូវតែខំប្រឹងរៀនសូត្រជា ឥតឈប់ ។

អត្ថសញ្ហិតា វាចា ពាក្យប្រកបដោយប្រយោជន៍ ។ ជន អ្នកស្រឡាញ់សេចក្ដីសុខ-ចំរើន និយាយតែសំដីណាដែលប្រកបដោយ ប្រយោជន៍ ជាសំដីមានតម្លៃឲ្យអ្នកស្ដាប់ចូលចិត្តចង់ស្ដាប់, ហើយអ្នក ស្ដាប់នោះ យកទៅធ្វើតាម ប្រតិបត្តិតាមទៅ ក៏រមែងកើតផលកើត ប្រយោជន៍ ។ សំដីយ៉ាងនេះ ចាត់ជាសំដីបានការ ជាសំដីអ្នកប្រាជ្ញ ។

ព្រះបរមសាស្ដា ទ្រង់ទេសនាដឹកនាំវេនេយ្យសត្វ ឲ្យឃើញដោយ បញ្ញាថា យ៉ាងនេះជាធម៌ យ៉ាងនេះមិនមែនជាធម៌, ទ្រង់ពន្យល់ឲ្យលះ អកុសលចេញ ហើយឲ្យសមាទានយកកុសលធម៌វិញ ឲ្យគាប់បាន ឲ្យរើសយកគុណធម៌នោះៗ ទ្រង់បណ្ដុះសេចក្ដីរាប់អានរបស់មហាជនទាំង គ្រហស្ថទាំងបព្វជិតឲ្យមានកំឡាំងតាំងនៅអស់កាលដ៏យូរអង្វែង ។ ព្រះពុទ្ធសាសនាដែលនឹងអាចតាំងនៅបានរហូតមកដល់សព្វថ្ងៃនេះ ក៏ អាស្រ័យ ព្រះពុទ្ធវាចា ជាសច្ចវាចា ជាអត្ថសញ្ហិតា វាចា, វាចាពិត, វាចាមានប្រយោជន៍ ។ វាចាមានប្រយោជន៍នេះ ជាសំដីកាត់ថ្លៃពុំបាន ។ ការពោលពាក្យពីរោះយ៉ាងនេះ ចាត់ជាសង្គហទី ២ ។

ទី ៣ - អត្ថចរិយា គឺការប្រព្រឹត្តជាប្រយោជន៍ដល់គ្នានឹងគ្នានោះ គឺ បើប្រសិនជាឲ្យ ឬនិយាយពាក្យពីរោះ ជាគុណជាប់ចិត្តចងមេត្រីចុកបានយ៉ាងស្អិតក៏ពិត, ប៉ុន្តែបើជាមនុស្សចេះតែមើលបំណាំគ្នាទៅវិញទៅមក មិនប្រព្រឹត្តប្រយោជន៍ដល់គ្នានឹងគ្នា គឺជាមិនជួយប្រយោជន៍ឲ្យ មិនប្រាប់ឧបាយឲ្យកើតប្រយោជន៍ឲ្យ គ្រាន់តែឲ្យរបស់ប្រើប្រាស់ និងនិយាយតាមការសម្រួលប៉ុណ្ណោះ ការជិតស្និទ្ធនោះក៏នឹងសាបរលាបទៅវិញបានដោយងាយ ។ ព្រោះហេតុនោះ អត្ថចរិយា ការប្រព្រឹត្តជាប្រយោជន៍ដល់គ្នានឹងគ្នានេះ ក៏ជាគុណយ៉ាងសំខាន់គាបយើងយោងគ្នានឹងគ្នាឲ្យទៅកាន់សេចក្ដីសុខ-ចំរើនតរៀងទៅបាន ។

ឯការយើងយោងឲ្យប្រយោជន៍ដល់គ្នានឹងគ្នានោះ ដូចជាមាតាបិតាខំខ្វល់ខ្វាយធ្វើប្រយោជន៍ឲ្យបុត្រធីតា គឺខំស្វះស្វែងរកទ្រព្យសម្បត្តិ ចំណេះវិជ្ជា ផ្ដល់ឲ្យបុត្រធីតាតាមជាន់តាមថ្នាក់; ចំណែកបុត្រធីតាវិញក៏ជួយខ្វល់ខ្វាយកិច្ចការរបស់មាតាបិតា គឺជាត្រូវចិញ្ចឹមគាត់ដោយការតបគុណ ។ ឥស្សរជនជួយធុរៈដល់អ្នកដែលត្រូវការពឹងពាក់ព្យាបាលទំនុកបម្រុងឲ្យមានគ្រឿងឈ្មោះយសសក្តិ ប្រាកដក្នុងទីប្រជុំជន, រមែងជាទីនិយមរាប់អានរបស់អ្នកពឹងពាក់, អ្នកដែលពឹងពាក់សោតទៀតក៏ត្រូវធ្វើកិច្ចការរបស់លោកឲ្យសម្រេចតាមចំនងដែលលោកប៉ុនប៉ង ធ្វើខ្លួនឲ្យលោកជឿជាក់នឹងទុកចិត្តបាន ឲ្យលោកស្រឡាញ់រាប់រកតែខ្លាំងឡើង ។

មិត្រសំឡាញ់ ក៏ត្រូវជួយខ្វល់ខ្វាយកិច្ចធុរៈគ្នាទៅវិញទៅមក ដោយកម្លាំងកាយខ្លះ ដោយកំឡាំងវាចាខ្លះ កំឡាំងគំនិតខ្លះ កំឡាំងទ្រព្យខ្លះ ឲ្យសមតាមចំនងពុទ្ធភាសិតថា អត្ថម្ហិ ជាតម្ហិ សុខា សហាយា មិត្រសំឡាញ់ទាំងឡាយ កាលបើធុរៈកើតឡើង, រមែងជួយនាំឲ្យបានសេចក្ដីសុខ ទើបខាងមេត្រីបក្ខរាប់រកគ្នាយ៉ាងស្និទ្ធ ៗ សម្បញ្ញាតិក៏ដូចគ្នា ត្រូវតែជួយធុរៈគ្នាតាមលំដាប់ញាតិ, មិនថាបាច់ញាតិសាច់សាលោហិតជិតគ្នាទេ ឲ្យតែរួមជាតិជាមួយគ្នា ក៏ត្រូវតែជួយផ្ដល់ប្រយោជន៍ឲ្យតាមសមគួរ យ៉ាងនេះទើបរាប់រកគ្នាទៅពេលមុខបានស្រួលល្អ ៗ ឯការដឹកនាំកងផ្សេងមិនទៀតសោត ក៏ត្រូវបបួលគ្នាឲ្យបរិច្ចាគធនធានធ្វើកុសល ដើម្បីនឹងញុំាងគ្នាឲ្យស្រុះស្រួលនឹងគ្នាក្នុងការបុណ្យនោះ ឲ្យបេះស្និទ្ធស្នាលគ្នាតទៅ ៗ ដូចជាអ្នកមានសីលធម៌ល្អ អាចដឹកនាំអ្នកឥតសទ្ធា ឲ្យមានសទ្ធា ឥតសីល ឲ្យមានសីល កំណាញ់ស្វិតស្វាញ ឲ្យមានចិត្តទូលាយបរិច្ចាគទ្រព្យធ្វើបុណ្យ អ្នកល្ងង់ខ្លៅឲ្យមានប្រាជ្ញា ។ យ៉ាងនេះឈ្មោះថាប្រព្រឹត្តប្រយោជន៍ដល់គ្នានឹងគ្នា រាប់ថាជាសង្គហ ទី ៣ ។

ទី ៤- សមានត្តតា ការជាអ្នកតាំងខ្លួនឲ្យស្មោះស្មើទៅនឹងបុគ្គលផងគ្នាតាមសមគួរនោះ, គឺបុគ្គលសម្បីគ្រាន់តែឲ្យ ឬនិយាយពាក្យពិរោះព្រមទាំងជួយខ្វល់ខ្វាយធ្វើប្រយោជន៍ ឬណែនាំប្រាប់ប្រយោជន៍ដល់គ្នានឹងគ្នាតែប៉ុណ្ណោះ, តែបើមិនបេះរៀបចំខ្លួនប្រាណឲ្យសមតាម

អត្តភាព គឺមិនស្គាល់ធំ-តូច-ខ្ពស់-ទាប ជាអ្នកប្រកាន់មានះ ក្អេងក្អាង មើលងាយគេ ធ្វើឫកពាក្រអឺតក្រអោងយ៉ាងនេះទេ, សេចក្ដីរាប់អានគ្នា ក៏ទំនងសាបរលាបទៅវិញ ។ លុះតែការស្រីយខ្លួនសេចក្ដីស្មោះស្ម័គ្រ តាំងខ្លួនឲ្យសមតាមអត្តភាពផង, ទើបសេចក្ដីរាប់អាននោះនឹងមានកម្លាំងអាចតាំងនៅបានយូរអង្វែងទៅបាន ។

ជនអ្នកមានវ័យតិច សូម្បីវិសេសជាងដោយយសសក្ដិ ដោយអំណាច ដោយភោគសម្បត្តិ ដោយបរិវារប៉ុនណា, ក៏ត្រូវតាំងខ្លួនឲ្យសមតាមវ័យភាព យសសក្ដិជាដើមប៉ុណ្ណោះ, គឺត្រូវតែគំនាប់គាប់គួរដល់ជនអ្នកមានវ័យចំរើនជាងខ្លួន, ពីដើមមកធ្លាប់រាប់អានយ៉ាងណា ទាំងក្រោយមកក៏ត្រូវរាប់អានយ៉ាងនោះ ។ ជនទាំងឡាយ ដែលបានទទួលសេចក្ដីគោរពកោតក្រែងយ៉ាងនេះហើយ, ក៏រមែងស្រឡាញ់ពេញចិត្តសំដែងការរាប់រកទៅវិញ ។

ពួកញាតិដែលមានវ័យស្មើៗគ្នាទៀតសោត ក៏ត្រូវសំដែងសេចក្ដីរាប់អានគ្នាដោយពេញចិត្តចំពោះញាតិផងគ្នា, ទោះនិយាយស្ដីក្ដី ធ្វើការងារអ្វីក្ដី ដេក-ដើរ-ឈរ-អង្គុយក្ដី ក៏ត្រូវប្រព្រឹត្ត ត្រូវធ្វើ ត្រូវនិយាយស្ដីឲ្យសមតាមអត្តភាពរបស់ខ្លួន ។ ញាតិដែលជាអ្នកធំមានមេត្តារាប់រកញាតិដែលជាអ្នកតូច ស្និទ្ធស្នាលគ្នាទៅវិញទៅមកជួយគ្នាទៅវិញទៅមក ដើម្បីគាំពារវង្សត្រកូលរបស់ខ្លួនឲ្យចំរើន; សេចក្ដីសាមគ្គីនៃញាតិនេះ,

រមែងញុំាងសេចក្ដីសុខឲ្យកើតមានឡើងដល់ពួកគ្នា; ដូចមានពុទ្ធភាសិតថា
ធីរោ ច សុខសំវាសោ ញាតីនំវ សមាគមោ អ្នកប្រាជ្ញដែល
មានមនុស្សមកនៅរួមជាមួយហើយ, រមែងញុំាងសុខឲ្យកើតដូចជាការ
ជួបជុំ គឺសេចក្ដីព្រមព្រៀងនៃពួកញាតិដូច្នោះដែរ ។

មួយទៀតជនដែលអាស្រ័យនៅក្នុងគណៈដូចជាភិក្ខុសង្ឃ ដែល
អាស្រ័យនៅជាមួយគ្នាបាន ក៏ដោយអំណាចមានធម៌ស្មើគ្នា ។ បើមិន
ដូច្នោះទេ ក៏មិនគប្បីនឹងកេ្សាមគ្គីឲ្យគង់នៅបានឡើយ ។ ព្រោះហេតុ
នោះ បានជាលោកដែលជាប្រធាននៃគណៈត្រូវចំក្ដីដើម្បីឲ្យមនុស្សទាំង-
ឡាយក្នុងគណៈ និយមធ្វើតាមសណ្ដាប់ធ្នាប់របស់គណៈ ក៏បាត់បង់នូវ
មនុស្សដែលល្មើសចេញ ហើយរក្សាសាមគ្គីរបស់គណៈឲ្យតាំងនៅមាំ
មួនឡើង ។

សមានត្តតានេះ បើធ្វើឲ្យសមដល់មោតុផលរបស់បុគ្គលឬគណៈ
ហើយ រមែងយឹតយោងបុគ្គលនឹងគណៈនោះ ឲ្យតាំងនៅក្នុងសាមគ្គីធម៌
យ៉ាងដិតស្អិទបាន នេះបាត់ជាសង្គហទី ៤ ។

សង្គហធម៌ទាំង ៤ ចប់តែប៉ុណ្ណេះ ។

ខាលបើចប់ធម៌ទេសនាហើយសូមផ្សាយចំណែកកុសល ដល់អស់
លោក-អ្នកទាំងឡាយ ដែលឋិតនៅក្នុងកម្ពុជរដ្ឋទាំងមូល សូមឲ្យបាន
សេចក្ដីសុខ-ចំរើនតរៀងទៅ ។

ទុក្ខប្បត្តា ច និទ្ទុក្ខា  ភយប្បត្តា ច និព្ភយា

សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ ទាណិនោ ។

*សព្វសត្វទាំងឡាយដែលដល់នូវសេចក្តីទុក្ខ ក៏ឲ្យបាត់ទុក្ខទៅ, ដែលដល់នូវភ័យ ក៏ឲ្យបាត់ភ័យទៅ, ដែលដល់នូវសេចក្តីសោក ក៏ឲ្យបាត់សោកទៅ (ដោយអំណាចធម្មទេសនានេះ) ។*

សំដែងអំពីសង្គហធម៌ ៤ យ៉ាងចប់តែប៉ុណ្ណេះ ។

---

យុវចរិយាគាថា

# ព្រះគ្រូបញ្ញាលិខិត កៅ-សឹម

គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ រៀបរៀង

(តមក)

---

ព្រះឥន្ទ្រជាបុរេហេតុនោះក៏បានចុះមកឲ្យឆ្នាំង ១ ដែលសម្រាប់ប្រសិទ្ធិជាទីឲ្យសម្រេចប្រយោជន៍គ្រប់យ៉ាង ហើយប្រាប់ថា "នែកូន ! ឯងចូររក្សាឆ្នាំងនេះទុក កុំឲ្យបែកធ្លាយ កាលបើឆ្នាំងនេះ មិនបានបែកធ្លាយទេ ឯងនឹងសម្បូរហូរហៀរទៅដោយទ្រព្យមិនខាន ចូរឯងកុំប្រមាទឲ្យសោះ" ហើយក៏ត្រឡប់ទៅកាន់ទីលំនៅរបស់ខ្លួនវិញ ។ ចាប់ដើមតាំងពីថ្ងៃនោះមកកូននោះចេះតែផឹកស្រាស្រវឹងមិនដឹងខ្លួន ហើយស្ទុះទៅចាប់ឆ្នាំងនោះលើកបោះគ្រវែងទៅលើអាកាស ស្ទុះទៅផើងទទួលខុស ក្តាត់ចំណាប់ចាប់មិនជាប់បូកធ្លាក់ចុះទៅលើផែនដីបែកខ្ទេចទៅ ។ កូននោះធ្លាក់ទៅជាមនុស្សទ្រីទាល់ក្រ ស្លៀកកំណាត់សំពត់មួយទៀត កាន់អម្បែងដើរសុំទានគេស៊ី ទៅដេកស្លាប់នៅក្បែរសំយាបផ្ទះអ្នកដទៃ (គេថាខ្មោចបាវ ក៏បបួលគ្នាអូសពោលទៅ) ។

ចប់រឿងកូនព្រះពោធិសត្វ ។

---

# រឿងក្មួយអនាថបិណ្ឌិកសេដ្ឋី

សេចក្តីថាៈ ក្មួយរបស់អនាថបិណ្ឌិកសេដ្ឋី បំផ្លាញទ្រព្យ ៤០ កោដិជារបស់ដែលមាតាបិតាទុកឲ្យ វិនាសដោយហេតុតែផឹកសុរា ហើយទៅកាន់សំណាក់សេដ្ឋី ។ ឲ្យមួយពាន់កហាបណៈមកបង្គាប់ថាៈ " ឯងចូរយកទ្រព្យនេះទៅធ្វើជំនួញចុះ " ។ ក្មួយនោះយកទ្រព្យនោះទៅចាញ់ស្រាផឹកអស់ហើយ ទៅកាន់សំណាក់សេដ្ឋីម្តងទៀត សេដ្ឋីបានឲ្យ ៥០០ កហាបណៈមកទៀត ក៏យកទៅចាញ់ស្រាផឹកទាល់តែអស់ សេដ្ឋីបានឲ្យសំពត់សាដកមានសាច់ក្រាស់ ២ គូមកទៀត ក៏យកទៅឲ្យវិនាសអស់ទៀត ទើបសេដ្ឋីប្រើមនុស្សឲ្យចាប់ក្មួយនោះទាញកន្ត្រាក់ច្រានបណ្តេញចេញអំពីផ្ទះ ។

ឯក្មួយនោះឥតមានអ្នកណាជាទីពឹងសំណាក់អាស្រ័យ ក៏ទៅដេកស្លាប់ក្បែរសំយាបផ្ទះអ្នកដទៃ មនុស្សទាំងឡាយនាំគ្នាទាញអូសខ្មោចនោះយកទៅចោលខាងក្រៅស្រុកទៅ ។

ហេតុនេះហើយ អ្នកផឹកស្រាគួរពិចារណាតាមរឿងដែលពណ៌នាមកជាទិដ្ឋានុគតិ មិនត្រូវយកតម្រាប់តាមទៅអនាគតឡើយ ។

ចប់បានសោណ្ឌាតែប៉ុណ្ណេះ ។

# ទោសកើតអំពីអង្គុយឬឈរមាន ៦ យ៉ាង (១)

មនុស្សយើងត្រូវស្គាល់ប្រមាណក្នុងកាលដែលចូលទៅគាល់សំណាក់លោកអ្នកធំដោយមានកិច្ចណាមួយ គប្បីចៀសវាងទោសដែលកើតអំពីអង្គុយ ឬឈរខុសទំនង នាំឲ្យជាទំនាស់អធ្យាស្រ័យរបស់អ្នកធំ គំនុំគុំគួនចិត្តនាំឲ្យខូចភាគប្រយោជន៍ខាងមុខ ដូចមានមាតិកាបញ្ជាក់ប្រាប់ឈ្មោះទោសឲ្យបានល្អតទៅនេះ ។

១ - អង្គុយឬឈរឆ្ងាយពេក (អតិទូរ)

២ - អង្គុយឬឈរជិតពេក (អច្ចាសន្ន)

៣ - អង្គុយឬឈរពីខាងលើខ្យល់ (ឧបរិវាត)

៤ - អង្គុយឬឈរខ្ពស់ជាងពេក (ឧន្នតប្បទេស)

៥ - អង្គុយឬឈរចំមុខពេក (អតិសម្មុខា)

៦ - អង្គុយឬឈរចំពីខាងក្រោយពេក (អតិបច្ឆា) ។

ទី ១ ដែលថាអង្គុយឬឈរឆ្ងាយពេកនោះ គួរជ្រាបថា: កាលបើត្រូវការអ្នកធំសួរ ឬខ្ញុំនិយាយជំរាបជូនរឿងអ្វីៗ គង់តែប្រែសំដីសម្លេងសួរនឹងឆ្លើយធ្ងន់ទៅវិញទៅមកឲ្យលាន់ឮខ្លាំង ទើបដឹងការណ៍នោះៗ ច្បាស់ ។

---

១ បឋមសម្ពោធ... ត្រង់វេរញ្ជកណ្ឌវណ្ណនា ។

ទី ២ ដែលថា អគ្និយឬឈរជិតពេក ជាហេតុនាំឲ្យអប្បយសដល់លោកអ្នកធំ ព្រោះខ្លួនបុណ្យតូចស័ក្តិទាបសាបអំណាចមិនអាចលើកអត្តភាពរបស់ខ្លួនឲ្យស្មើ ហាក់ដូចជាស៊ូទស្សាំលេងដំណាលគ្នាបុកគា ទទឹងអ្នកធំនោះៗ ពុំនោះសោត បណ្ដាលនាំឲ្យស្អុះស្អាប់កើតសេចក្ដីធុញទ្រាន់ ទាំងធ្វើការអ្វីមួយមិនកើត ។

ទី ៣ ដែលថាអគ្និយឬឈរពីលើខ្យល់នោះ ត្រូវដឹងថា: ក្លិនខ្លួនយើងដែលបក់ផ្សាយចំហាយចេញទៅ នាំឲ្យជាសត្រូវប្រៀតប្រៀនដល់លោកអ្នកធំ មិនឲ្យរីករាយសប្បាយចិត្តដោយសារក្លិននោះៗ ។

ទី ៤ ដែលថាអគ្និយឬឈរខ្ពស់ជាងអ្នកធំនោះ ត្រូវដឹងថា: ធម្មតាមនុស្សយើងតែងសំដែងឫកពា ប្រកបដោយធម៌អស្មិមានៈ ប្រែអាការពុំសូវគោរពកោតខ្លាច ចង់ជាន់ឡើងឫកពា ដូចស្មើនឹងអ្នកធំ ។

ទី ៥ ដែលថាអគ្និយឬឈរចំមុខពេកនោះ គួរប្រាប់ថា: អ្នកធំឬខ្លួនអ្នកតូចត្រូវការមើលមុខ គោរពតែសំឡឹងចំមុខពេក ហាក់ដូចជានាំឲ្យកើតហេតុសេចក្ដីរឹងត្អឹងទៅវិញទៅមក ។

ទី ៦ ដែលថាអគ្និយឬឈរចំពីខាងក្រោយពេកនោះ គួរដឹងថា: អ្នកធំរលោត្រូវការនិយាយ ឬចង់ឃើញមុខ គោរពតែងាកក្រោយទៅមើលទើបឃើញមុខស្គាល់គាការគេរៀបរាប់សព្វគ្រប់ ជាហេតុនាំឲ្យមានសេចក្ដីលំបាកដល់លោកអ្នកធំ ។

គឺកង្វះបច្ច័យនិយមរបស់អ្នកបួសវិញនោះ គួរស្គាល់ឋាន ២ យ៉ាង

១- អជ្ឈត្តដ្ឋាន ឋានខាងក្នុង

២- ពាហិរដ្ឋាន ឋានខាងក្រៅ

ឯឋានខាងក្នុងនោះ គឺទីនៅក្នុងវត្តមាននិយ ដេក-ដើរ-ឈរ-អង្គុយ ត្រូវឲ្យមានសម្បជញ្ញៈ ការដឹងខ្លួន ស្គាល់ប្រមាណក្នុងឥរិយាបថទាំង៤ នោះផង គួរយ៉ាង ភិក្ខុ-សាមណេរដែលចូលទៅកាន់សំណាក់ព្រះឧបជ្ឈាយាចារ្យរបស់ខ្លួនជាដើមអង្គុយគាល់ អង្គុយស្តាប់ធម៌ទេសនា ត្រូវប្រើឥរិយាបថ ឲ្យរម្យទម្យរៀបរយកុំឲ្យបង្រិះបង្រួស់ទាស់បង្គុយរាំងគេ ត្រូវបន្ទន់កាយឲ្យមានសភាពបសាទៅតាមទំនួល មិនត្រូវអង្គុយបោងបោង បញ្ឈរក្បាលជង្គង់ ប្រកដៃទល់បង្កា ប្រកាំងៀងបញ្ចៀង ខ្លួនទំរេតផ្អែក ឬក៏ចាក់ដៃម្ខាងផ្ទប់ទឹងកន្ទួលក្រោងខ្លួនធ្វើខ្លួនហាក់ដូចជា ត្រូវ១ផង ពុំនោះសោតនិយាយការអ៊ឹមអឹម ឆាដៃកាំសចុះកាំសឡើង ធ្វើខ្លួនហាក់ដូចជាចេះព្រហែលទឹងគ្រូឧបជ្ឈាយាចារ្យនោះផង, នេះហើយជាឆាការរបស់មនុស្សព្រះហ៊ីនកោងកាច ធ្វើខ្លួនឲ្យមានអំណាចខ្ពស់ដូចជាអកធំ គួរនិយមចុះក្នុងទោសដូចបានពោលមកហើយនោះ ។

ឯឋានខាងក្រៅនោះ គឺទីខាងក្រៅអំពីទីវត្ត កាលបើភិក្ខុ-សាមណេរទទួលនិមន្តទាយក-ទាយិកា ដោយមានកិច្ចធុរៈបុណ្យទានជាដើម នៅទីផ្ទះគេក្តីទីកន្លែងណាមួយ ដែលចេញទៅផុតអំពីទីឧបចាររបស់

វត្តនោះ គេនឹងរៀបចំឥរិយាបថឲ្យមានរបៀបរៀបរយទៅតាមលំដាប់សេក្ខរបស់ខ្លួន ហើយសឹមដើរចេញទៅ កុំជក់បារី ទំពាស្លា ពោលចរចាគ្នានិយាយរកសៃដ.ដើងដើរទៅនោះឡើយ ត្រូវដើរទៅជាជួរ ៗ ជាទីញុំាងសំរស់លឲ្យកើតសេចក្ដីជ្រះថ្លាដល់ជនទាំងពួង ។

លុះដល់ទៅផ្ទះទាយកគេនិមន្តឡើងលើអាសនៈ គប្បីមើលមើលចេនស្លាំសិន កុំឲ្យរួសរាន់ពេក ឲ្យសមគួរដល់ច្បាប់វិន័យ[១] ត្រូវពិចារណាបំពោះអាសនៈ មានកន្ទេល ព្រំ ហៀមជាដើមនោះផង ៗ ដែលនឹងពិចារណាអាសនៈនោះ គេនឹងពិចារណាដល់គ្រឿងបរិក្ខារប្រើប្រាស់ដូចផ្តិលទឹក តែទឹក ជើងពានដាក់ស្លាបារី ក្បាក់ដាក់ប៉ាន់តែ កន្ទោរស្លាម៉ៃដែលគេរៀបចូលកន្លែងនោះ ហើយសឹមដាក់អង្គុយ លុតជង្គង់ចុះជាមុនតាមទំនួល បង្អោនមុខស្រមូលចុះបន្តិច តែកុំក្រុបកនឹងពេលដែលអង្គុយនោះឲ្យសោះ ត្រូវមានសតិសម្បជញ្ញៈឲ្យខ្ជាប់ ទើបបានឈ្មោះថាបព្វជិតនិយម ៗ ព្រោះតាមបព្វជិតខ្លះច្រើនពុំសូវប្រយ័ត្នស្គាល់ប្រមាណ កនឹងពេលដែលឡើងកាន់អាសនៈ នៅផ្ទះទាយក-ទាយិកាឥតមានគំនិតគិតពិចារណាសោះឡើយ ពព្រាំងពព្រើត សស្វើកសស្វាក់ ក្រែងក្រមបន្ទន់ឈយប្រើខបាយហាក់ដូចជាខ្លាចទាយកម្ចាស់ទានណាស់ ឬក៏សំដែងសាចារហាក់ដូចជាគោរពទាយកជាម្ចាស់ទាន

(មានត)

១ ត្រូវសំឡឹងមើល ១ ដូរនឹមជាគិរប ៗ